A/HRC/21/63

អង្គការសហប្រជាជាតិ

មហាសន្និបាត

ចែកចាយ : ទូទៅ
១៦ កក្កដា ២០១២

អត្ថបទដើម ៖ អង់គ្លេស

ក្រុមប្រឹក្សាសិទ្ធិមនុស្ស
សម័យប្រជុំលើកទីម្ភៃមួយ
របៀបវារៈចំណុចទី១០
ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព

## របាយការណ៍របស់អ្នករាយការណ៍ពិសេសនៃលោកអគ្គលេខាធិការ អ.ស.ប ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី

*សេចក្ដីសង្ខេប*

ឆ្នាំដែលស្ថិតក្រោមការពិនិត្យមើលនេះ គឺជាខួបលើកទី២០ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ ដែលពង្រឹងដំណើរការសន្តិភាពក្នុងប្រទេសកម្ពុជា។ អាណត្តិរបស់អ្នករាយការណ៍ពិសេសសំរាប់សិទ្ធិមនុស្សនៅកម្ពុជាមានដើមកំណើតមកពីកិច្ចព្រមព្រៀងទាំងនេះ។ ខណៈដែលប្រទេសកម្ពុជាកាន់តែខិតជិតទៅរកការបោះឆ្នោតទូទៅនៅឆ្នាំក្រោយនាខែកក្កដា ឆ្នាំ២០១៣ វាក៏ជាឱកាសមួយ ដើម្បីពិចារណាអំពីការរីកចំរើនដែលមានក្នុងរយៈពេល២០ឆ្នាំ កន្លងមកនេះ និងដោះស្រាយបញ្ហាប្រឈមដែលនៅតែនៅទ្រឹងក្នុងប្រព័ន្ធអភិបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រទេសកម្ពុជាបានឆ្លងកាត់ផ្លូវមួយដ៏វែងឆ្ងាយ ចាប់តាំងពីមានកិច្ចព្រមព្រៀងទាំងនេះ ហើយបានឆ្លងកាត់ព្រឹត្តិការណ៍សំខាន់ៗជាច្រើនក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ។ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាតិ ឬសភាតាមកាលកំណត់ចំនួនបួនដងហើយ ចាប់តាំងពីពេលនោះមក និងការបោះឆ្នោតថ្នាក់ក្រោមជាតិឬឃុំ/សង្កាត់ ចំនួនបីដង។ ការបោះឆ្នោតឃុំ/សង្កាត់ចុងក្រោយគេត្រូវបានរៀបចំឡើងកាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២ ហើយការបោះឆ្នោតសភាជាតិ នឹងត្រូវរៀបចំធ្វើក្នុងខែកក្កដា ឆ្នាំ២០១៣។ ទាំងអស់នេះគឺជាព្រឹត្តិការណ៍សំខាន់ៗ នៅក្នុងដំណើរលទ្ធិប្រជាធិបតេយ្យនីយកម្ម

របស់ប្រទេសកម្ពុជា។ ដោយសារតែបរិបទនេះហើយ ទើបនៅក្នុងដំណើរបេសកកម្មលើកទី៦ របស់ខ្លួនមកកាន់ប្រទេសកម្ពុជាកាលពីខែធ្នូ ឆ្នាំ២០១១ អ្នករាយការណ៍ពិសេស បានផ្តោតលើការវាយតម្លៃសិទ្ធិមនុស្សនៃស្ថាប័នរដ្ឋដែលពាក់ព័ន្ធនឹងដំណើរការបោះឆ្នោតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមានច្បាប់ គោលនយោបាយ និងការអនុវត្តន៍នានាដែលនៅជាធរមានចំពោះការបោះឆ្នោត ក្នុងបរិបទនៃកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា ដើម្បីធានានូវការបោះឆ្នោតតាមកាលកំណត់ ដោយសេរី និងយុត្តិធម៌ ហើយជាបេសកកម្មមួយប្រកបដោយផ្លែផ្កា។ បេសកកម្មលើកទី៧ ដែលបានធ្វើពីថ្ងៃទី៤ ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ បានផ្តោតការយកចិត្តទុកដាក់លើផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច លើសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងប្រទេសកម្ពុជា ហើយជាប្រធានបទនៃរបាយការណ៍ដាច់ដោយឡែកមួយ បន្ថែមលើរបាយការណ៍នេះ។

ដោយផ្អែកលើព័ត៌មានដែលគាត់បានទទួលក្នុងអំឡុងពេលនៃបេសកកម្មលើកទី៦ របស់គាត់ អ្នករាយការណ៍ពិសេស យល់ឃើញថា កំណែទម្រង់មួយចំនួនគួរតែធ្វើដើម្បីធានាថាការបោះឆ្នោតនៅកម្ពុជាគឺសេរី និងយុត្តិធម៌ ហើយប្រជាជនកម្ពុជាអាចអនុវត្តសិទ្ធិរបស់ពួកគាត់ ចំពោះអភិបាលកិច្ចប្រជាធិបតេយ្យក្នុងបរិយាកាសនយោបាយសេរីមួយ។ គាត់មានការព្រួយបារម្ភ ពីចន្លោះសមត្ថភាពដែលនៅតែមាននៅក្នុងដំណើរការបោះឆ្នោតក្នុងប្រទេសកម្ពុជា ដើម្បីរៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ អាចប្រព្រឹត្តិទៅបានតែនៅពេលដែលមានបរិយាកាសនយោបាយសេរីមួយ ហើយប្រជាពលរដ្ឋ អាចអនុវត្តសិទ្ធិ និងសេរីភាពរបស់ពួកគាត់បាន ដូចជាសេរីភាពនៃការបញ្ចេញមតិ និងការជួបជុំគ្នា និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត។ ដើម្បីរៀបចំការបោះឆ្នោតដែលគួរឱ្យជឿទុកចិត្តមួយបាន រដ្ឋាភិបាលត្រូវធានាស្តង់ដារខ្ពស់ ស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន តាំងនៅមុនពេល ក្នុងអំឡុងពេល និងក្រោយការបោះឆ្នោត។

ប្រទេសកម្ពុជាបានទទួលផលប្រយោជន៍នៃអនុសាសន៍យ៉ាងច្រើន ដែលធ្វើដោយទីភ្នាក់ងារទ្វេភាគីនានា ព្រមទាំងទីភ្នាក់ងារពហុភាគី ឱ្យធ្វើកំណែទម្រង់ពីដំណើរការបោះឆ្នោតក្នុងទស្សនៈនៃកង្វះខាតដែលនៅតែមានពីការបោះឆ្នោតកាលពីលើកមុនៗ។ ប៉ុន្តែ គួរឱ្យសោកស្តាយដែលអនុសាសន៍ភាគច្រើននៃអនុសាសន៍ទាំងអស់នេះ នៅតែមិនទាន់បានអនុវត្តនៅឡើយ។ ដូច្នេះ របាយការណ៍នេះ ផ្តោតការយកចិត្តទុកដាក់លើការវាយតម្លៃពីឯករាជ្យភាព និងសមត្ថភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត ពីព្រោះស្ថាប័នរដ្ឋមួយចំនួន ទទួលខុសត្រូវក្នុងការលើកកម្ពស់សិទ្ធិរបស់ប្រជាពលរដ្ឋ។ មានចំណុចខ្វះខាតធំៗមួយចំនួននៅក្នុងរដ្ឋបាលនៃការបោះឆ្នោត ហើយចំណុចខ្វះខាតខ្លះ ទាមទារឱ្យមានកំណែទម្រង់ជាបន្ទាន់ និងខ្លះទៀតត្រូវធ្វើក្នុងរយៈពេលយូរ ដើម្បីធ្វើឲ្យប្រជាពលរដ្ឋក្នុងប្រទេសមានការទុកចិត្តបន្តិចម្តងៗ លើដំណើរការបោះឆ្នោត និងលើការងាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ដោយគិតពីចំណុចនេះហើយ ទើបអ្នករាយការណ៍ពិសេស ផ្តល់អនុសាសន៍

ជាសេរី ក្នុងរបាយការណ៍នេះ ក្នុងន័យស្ថាបនាមួយ ឱ្យកែទម្រង់ដំណើរការបោះឆ្នោត និងសង្ឃឹមថា រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងអ្នកពាក់ព័ន្ធផ្សេងទៀត និងចាត់វិធានការដើម្បីអនុវត្តអនុសាសន៍ទាំងអស់នេះ។

ចំពោះផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ចលើសិទ្ធិរបស់ប្រជាពលរដ្ឋ អ្នករាយការណ៍ពិសេសយល់ឃើញថា ចំណាយរបស់មនុស្សលើសម្បទានបែបនេះ មានតំលៃខ្ពស់ណាស់។ គ្មានការពិគ្រោះយោបល់ និងការចរចាត្រឹមត្រូវ ក្នុងរឿងក្តីជាច្រើនជាមួយប្រជាពលរដ្ឋដែលរងគ្រោះ នៅពេលផ្តល់សម្បទានបែបនេះ បានក្លាយជាកង្វល់ចម្បងមួយ។ អ្នករាយការណ៍ពិសេស បានអំពាវនាវដល់រាជរដ្ឋាភិបាល ឲ្យផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី រហូតដល់ និងទាល់តែមានក្របខណ្ឌគោលនយោបាយសមស្របមួយ ដាក់ឱ្យអនុវត្ត ដែលបំពេញបានតាមស្តង់ដារនៃតម្លាភាព និងគណនេយ្យភាព និងអនុញ្ញាត្តិឲ្យប្រជាពលរដ្ឋរងគ្រោះអាចចូលរួមក្នុងការពិគ្រោះយោបល់ មុនពេលផ្តល់សម្បទានបែបនេះ។ អ្នករាយការណ៍ពិសេស សប្បាយរីករាយ នៅពេលដែលគាត់កំពុងបំពេញបេសកកម្មស្វែងរកការពិតលើកទី៧ របស់គាត់ក្នុងប្រទេសកម្ពុជា ដែលបានផ្តោតការយកចិត្តទុកដាក់លើសម្បទានដីសេដ្ឋកិច្ច នាយករដ្ឋមន្ត្រីបានចេញអនុក្រឹត្យមួយដោយប្រកាសឱ្យផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងដោយសន្យាពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់ឱ្យរួចហើយ។ អ្នករាយការណ៍ពិសេស សូមស្វាគមន៍ នូវសេចក្តីសម្រេចនេះ និងអំពាវនាវដល់រាជរដ្ឋាភិបាល ធ្វើឲ្យប្រាកដថាការពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់ឱ្យរួចហើយ ត្រូវមានការចូលរួម តម្លាភាព និងការរាប់បញ្ចូល។ របាយការណ៍បន្ថែមលើរបាយការណ៍នេះ មានការវិភាគអំពីចរិកលក្ខណៈ និងផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត និងអនុសាសន៍ជាសេរីរបស់អ្នករាយការណ៍ពិសេស ដើម្បីដោះស្រាយនូវផលប៉ះពាល់ជាអវិជ្ជមានពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត លើជីវភាពរស់នៅរបស់ប្រជាជន ជាពិសេស ប្រជាពលរដ្ឋក្រីក្រនៅតំបន់ជនបទ ជនជាតិដើម និងជនទាំងឡាយដែលមិនត្រូវបានរាប់រកពីសង្គម។

អ្នករាយការណ៍ពិសេសយល់ថា ប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍មួយ ដែលប្រាថ្នាចង់ប្រើប្រាស់ដី និងធនធានធម្មជាតរបស់ខ្លួន ឱ្យបានប្រយោជន៍បំផុត ដើម្បីធ្វើឲ្យប្រទេស អភិវឌ្ឍន៍ និងនាំមកនូវភាពរីកចំរើនជូនប្រជាជន។ គាត់ទទួលស្គាល់ថា កាលៈទេសៈជាប្រវត្តិសាស្ត្រ រួមទាំង គោលនយោបាយនៃរបបខ្មែរក្រហម បានបណ្តាលឲ្យមានការរីកសាយភាយនៃជំលោះដីធ្លី ដែលរដ្ឋាភិបាលកំពុងតែប្រឹងប្រែងដោះស្រាយ។ គាត់ក៏ទទួលស្គាល់ផងដែរថា មានកម្មវិធីសម្បទានដីសង្គមកិច្ច ដែលពាក់ព័ន្ធនឹងការបែងចែកដីជូនដល់អ្នកគ្មានដីធ្លី។ ទោះបីជាយ៉ាងណាក៏ដោយ អ្នករាយការណ៍ពិសេសយល់ឃើញថា សម្បទានដីគួរតែផ្តល់ឲ្យ និងគ្រប់គ្រងតាមក្របខណ្ឌច្បាប់ និងគោលនយោបាយត្រឹមត្រូវមួយ រួមមានការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេស សិទ្ធិរបស់ជនជាតិដើម ជនក្រីក្រនៅតាមតំបន់ជនបទ និងជនទាំងឡាយ ដែលមិនត្រូវបានរាប់រកពីសង្គម។

# មាតិការឿង


| | | កថាខ័ណ្ឌ | ទំព័រ |
|---|---|---|---|
| I. | សេចក្តីផ្តើម............................................................................................ | | ៥ - ៨ |
| II. | ការតាមដានពីការអនុវត្តអនុសាសន៍ក្នុងរបាយការណ៍មុនៗ......................... | | ៩ - ៩ |
| III. | ទំនាក់ទំនងដែលបានផ្ញើជូនរាជរដ្ឋាភិបាល................................................ | | ៩ - ១១ |
| IV. | ការវិវត្តន៍ថ្មីៗក្នុងវិស័យសិទ្ធិមនុស្ស........................................................ | | ១១ - ១៦ |
| | ក. សិទ្ធិដីធ្លី និងផ្ទះសម្បែង.......................................................................... | | ១១ - ១៤ |
| | ខ. សេរីភាពនៃការបញ្ចេញមតិ................................................................... | | ១៤ - ១៥ |
| | គ. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា................................................ | | ១៥ - ១៦ |
| | ឃ. អ្នកការពារសិទ្ធិមនុស្ស....................................................................... | | ១៦ - ១៦ |
| V. | តួនាទីរបស់ស្ថាប័នរដ្ឋ ជាពិសេស គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការលើកស្ទួយ និងការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងបរិបទនៃការបោះឆ្នោត...... | | ១៧ - ២៣ |
| | ក. ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់....................................................... | | ១៧ - ១៩ |
| | ខ. ការបោះឆ្នោតជាតិ............................................................................. | | ១៩ - ២០ |
| | គ. បញ្ហាប្រឈមសំខាន់ៗចំពោះដំណើរការបោះឆ្នោតនៅកម្ពុជា.......................... | | ២០ - ២៣ |
| VI. | សេចក្តីសន្និដ្ឋាន..................................................................................... | | ២៣ - ២៥ |
| VII. | អនុសាសន៍........................................................................................... | | ២៦ - ២៩ |

## I. សេចក្តីផ្តើម

១. នេះគឺជារបាយការណ៍លើកទី៤ របស់អ្នករាយការណ៍ពិសេសបច្ចុប្បន្ន ស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅប្រទេសកម្ពុជា ដែលបានដាក់ជូនតាមសេចក្តីសម្រេចលេខ១៨/២៥ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។

២. អ្នករាយការណ៍ពិសេស បានបំពេញបេសកកម្មស្វែងរកការពិតសិទ្ធិមនុស្សលើកទី៦ របស់គាត់ក្នុងប្រទេសកម្ពុជា ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១ ដោយផ្តោតការយកចិត្តទុកដាក់លើការវាយតម្លៃសិទ្ធិមនុស្សមួយនៃស្ថាប័នរដ្ឋដែលពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាន ច្បាប់ គោលនយោបាយ និងការអនុវត្តន៍ដែលនៅជាធរមានចំពោះការបោះឆ្នោត ក្នុងបរិបទនៃកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា ដើម្បីធានាឱ្យមានការបោះឆ្នោតទៀងទាត់ តាមកាលកំណត់ ដោយសេរី និងយុត្តិធម៌។ គាត់បានបំពេញបេសកកម្មលើកទី៧ មកប្រទេសកម្ពុជាចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ ដោយផ្តោតការយកចិត្តទុកដាក់លើផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត លើសិទ្ធិរបស់ប្រជាពលរដ្ឋ។ អ្នករាយការណ៍ពិសេស សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ចំពោះការផ្តល់កិច្ចសហប្រតិបត្តិការរបស់ខ្លួន ក្នុងអំឡុងពេលនៃបេសកកម្មលើកទី៦ និងទី៧ របស់គាត់ ហើយចំពោះការបង្ហាញពីឆន្ទៈរបស់ខ្លួន ធ្វើការងារជាមួយគាត់ ក្នុងលក្ខណៈស្ថាបនា។ គាត់មានការលើកទឹកចិត្ត តាមរយៈការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះបញ្ហាមួយចំនួនដែលអ្នករាយការណ៍ពិសេសបានលើកឡើង។អ្នករាយការណ៍ពិសេសក៏សូមអបអរសាទរដល់រាជរដ្ឋាភិបាលអំពីឋានៈជាប្រធានអាស៊ាននៅពេលបច្ចុប្បន្ននេះផងដែរ។

៣. ក្នុងអំឡុងពេលនៃបេសកកម្មរបស់គាត់ អ្នករាយការណ៍ពិសេសក៏មានបំណងវាយតម្លៃពីការរីកចំរើនក្នុងការអនុវត្តអនុសាសន៍ដែលមានក្នុងរបាយការណ៍លើកមុនៗរបស់គាត់ ដាក់ជូនដល់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងត្រួតពិនិត្យ និងដោះស្រាយបញ្ហាសិទ្ធិមនុស្សដែលកំពុងកើតមាននៅក្នុងប្រទេស ដូចជាជំលោះពាក់ព័ន្ធនឹងដីធ្លី សេរីភាពនៃការបញ្ចេញមតិ និងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងអំឡុងបេសកកម្មលើកទី៦ របស់គាត់ អ្នករាយការណ៍ពិសេសអាចជួបជាមួយតួអង្គជាច្រើន រួមមាន អ្នកប្រើប្រាស់សិទ្ធិ សង្គមស៊ីវិល គណៈបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ ក្រសួងការពារជាតិ អ្នកអត្ថាធិប្បាយ អ្នកការទូតនិងម្ចាស់ជំនួយបរទេស និងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ គាត់ក៏បានជួបជាមួយប្រជាពលរដ្ឋនៅតំបន់បឹងកក់ និងបុរីកីឡា ជនរងគ្រោះផ្សេងទៀតនៃការរំលោភសិទ្ធិមនុស្ស រួមមានជនជាតិដើម និងសហគមរងគ្រោះដោយជំលោះដីធ្លីសម្បទានដីសេដ្ឋកិច្ច និងការបណ្តេញចេញដោយបង្ខំនៅពេលថ្មីៗនេះ។

៤. អ្នករាយការណ៍ពិសេស មិនមានអភ័យឯកសិទ្ធិក្នុងការជួបជាមួយនាយករដ្ឋមន្ត្រីក្នុងបេសកកម្មទាំងពីរលើកទី៦ និងទី៧ ប៉ុន្តែគាត់សូមថ្លែងអំណរគុណដល់នាយករដ្ឋមន្ត្រីដែលបានបញ្ជូនបេសកជនម្នាក់មកជួប។

៥. អ្នករាយការណ៍ពិសេសមានសេចក្តីរីករាយ ដោយធ្វើការកត់សម្គាល់ពីភាពរីកចំរើនក្នុងវិស័យមួយចំនួនជាពិសេស ចំពោះសេចក្តីសម្រេចក្នុងការបន្តនូវការពិគ្រោះយោបល់បន្ថែមទៀតជាមួយអ្នកពាក់ព័ន្ធ អំពីសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងមានបំណងស្វែងរកការដោះស្រាយមួយដោយការចរចាពីជំលោះដីធ្លីនៅតំបន់បឹងកក់។ គាត់មានការលើកទឹកចិត្ត តាមរយៈតថភាពដែលថានាយករដ្ឋមន្ត្រីខ្លួនលោកផ្ទាល់បានផ្តួចផ្តើមឲ្យសាលាក្រុងភ្នំពេញ ផ្តល់កម្មសិទ្ធិដីច្រើនជាង៦០០ ប័ណ្ណកម្មសិទ្ធិ ជូនដល់ប្រជាជនដែលនៅសល់ក្នុងតំបន់ដែលបានកំណត់ចំនួន១២.៤៤ហិកតា។ អ្នករាយការណ៍ពិសេស សូមជម្រុញឲ្យរដ្ឋាភិបាលពង្រីកដំណើរការនៃការពិគ្រោះយោបល់ ដល់គ្រួសារទាំងឡាយដែលមិនបានរាប់បញ្ចូលក្នុងអនុក្រឹត្យលេខ១៨៣ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ និងដោះស្រាយជំលោះដោយសន្តិវិធី ដើម្បីជាការពេញចិត្តដល់គ្រប់ភាគីពាក់ព័ន្ធ។

៦. ជាការលើកទឹកចិត្តផងដែរ ដោយធ្វើការកត់សម្គាល់ថា ប្រទេសកម្ពុជាបានបន្តធ្វើការជាមួយយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ តាមរយៈការបង្ហើយសេចក្តីព្រាងរបាយការណ៍បន្ទាប់របស់ខ្លួន ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស។ ការងារដែលបានចាប់ផ្តើមដោយរាជរដ្ឋាភិបាល ក្នុងការរៀបចំអនុវត្តតាមអនុសាសន៍នៃដំណើរការត្រួតពិនិត្យជាសកលតាមកាលកំណត់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស(UPR) ក៏សក្តិសមនឹងទទួលបាននូវការកោតសរសើរផងដែរ។

៧. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កំណត់យ៉ាងរឹងមាំថាកម្ពុជាជាប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរីអាស្រ័យសភា ហើយការបោះឆ្នោតគឺជាស្នូលចំពោះលទ្ធិប្រជាធិបតេយ្យ។ ចាប់តាំងពីការបោះឆ្នោត ដែលរៀបចំដោយមានការជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិ ក្នុងឆ្នាំ១៩៩៣ មក ប្រជាជនកម្ពុជាទូទាំងប្រទេសបានក្រសោបយកលទ្ធិប្រជាធិបតេយ្យជាមួយនឹងសេចក្តីសង្ឃឹមយ៉ាងខ្ពស់ ហើយដំណើរទស្សនៈកិច្ចរបស់អ្នករាយការណ៍ពិសេសមកកាន់ប្រទេសកម្ពុជា ក្នុងកំឡុងបេសកកម្មលើកទី៦ របស់គាត់ បានបង្ហាញម្តងទៀត នូវការចូលរួមយ៉ាងខ្លាំងពីតួអង្គទាំងអស់ក្នុងការរៀបចំការបោះឆ្នោតដែលនឹងមកដល់ឆាប់ៗនេះ។ ប្រជាជនកម្ពុជានៅតាមដងផ្លូវ មើលឃើញអនាគតរបស់ពួកគេ ថាជាអ្នកប្រជាធិបតេយ្យ។ ក្រោយពីប្រវត្តិដ៏ខ្លីនៃលទ្ធិប្រជាធិបតេយ្យប្រៀបធៀបមួយនៅក្នុងប្រទេស ប្រជាជនកម្ពុជា មានទំលាប់ទៅនឹងទស្សនៈនៃការបោះឆ្នោត ហើយអ្នកទទួលខុសត្រូវក្នុងការរៀបចំការបោះឆ្នោត បានបង្កើនសមត្ថភាពរបស់ខ្លួន យ៉ាងច្រើនក្នុងការរៀបចំ។ បញ្ហាប្រឈមសំខាន់មួយ នឹងត្រូវកត់ចំណាំពីភាពស្រេកឃ្លានលទ្ធិ

ប្រជាធិបតេយ្យក្នុងស្រទាប់យុវវ័យរបស់ជាតិ ហើយអ្នករាយការណ៍ពិសេស មានការលើកទឹកចិត្តតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការបង្កើតកម្មវិធីធ្វើឲ្យជ្រួតជ្រាបដល់ប្រជាជនជាយុវវ័យដែលកំពុងតែមានចំនួនកើនឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។

៨. ទូទៅជាងនេះ ចាប់តាំងពីការបោះឆ្នោតលើកទី១ ក្នុងឆ្នាំ១៩៩៣ មក រដ្ឋាភិបាលកម្ពុជា និងអ្នកទាំងឡាយដែលធ្វើការក្នុងស្ថាប័នបោះឆ្នោត បានបង្កើនចំណេះដឹងរបស់ខ្លួនយ៉ាងច្រើន និងបានពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោត។ អ្នករាយការណ៍ពិសេស សប្បាយចិត្តដោយទទួលបានរបាយការណ៍ថា មន្ត្រីរាជការដែលធ្វើការក្នុងក្រសួងរដ្ឋាភិបាល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងស្ថាប័នរដ្ឋដទៃទៀត ព្រមទាំងសង្គមស៊ីវិល ទាំងអស់គ្នាសុទ្ធតែបានបង្ហាញនូវការយល់ដឹងយ៉ាងល្អមួយអំពីច្បាប់ និងការអនុវត្តដែលគ្រប់គ្រងលើដំណើរការបោះឆ្នោតក្នុងប្រទេសកម្ពុជា។

៩. ក្នុងអំឡុងពេលបេសកកម្មលើកទី៦ របស់គាត់ អ្នករាយការណ៍ពិសេស ទទួលបានព័ត៌មានជាច្រើនអំពីដំណើរការបោះឆ្នោត ពីប្រជាពលរដ្ឋ និងស្ថាប័ននានា ដែលជាញឹកញាប់មានទស្សនៈខុសគ្នាយ៉ាងខ្លាំង។ មនុស្សជាច្រើនបានបង្ហាញគាត់នូវព័ត៌មានអំពីការរីកចំរើនដែលកើតមានក្នុងទស្សវត្សកន្លងមកដើម្បីធានាថាការបោះឆ្នោត ស្របនឹងការអនុវត្តល្អៗជាអន្តរជាតិ និងស្តង់ដារសិទ្ធិមនុស្ស។ អ្នកដទៃទៀត បានបង្ហាញគាត់ នូវការចោទប្រកាន់ពីភាពមិនប្រក្រតី ឬបញ្ហាជាប្រព័ន្ធដែលធ្វើឱ្យខូចខាតដល់លទ្ធភាពរបស់កម្ពុជាក្នុងការរៀបចំការបោះឆ្នោត ដោយសេរី និងយុត្តិធម៌។

១០. ចំពោះការបោះឆ្នោតដែលនឹងមកដល់ឆាប់ៗនោះ អ្នករាយការណ៍ពិសេស បានផ្ញើលិខិតមួយច្បាប់គោរពជូននាយករដ្ឋមន្ត្រី កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដោយគូសបញ្ជាក់ពីការរកឃើញបឋម សេចក្តីសង្កេត និងអនុសាសន៍អំពីកំណែទម្រង់ការបោះឆ្នោត ហើយកំពុងតែរង់ចាំនូវការឆ្លើយតបពីរាជរដ្ឋាភិបាលចំពោះលិខិតរបស់គាត់។

១១. នៅក្នុងរបាយការណ៍នេះ អ្នករាយការណ៍ពិសេសបានធ្វើអនុសាសន៍ជាសេរីក្នុងន័យស្ថាបនា ដើម្បីកែទម្រង់ដំណើរការបោះឆ្នោត ហើយសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងអ្នករួមចំណែកដទៃទៀត និងអនុវត្តន៍តាមអនុសាសន៍ទាំងនេះ។

១២. បេសកកម្មលើកទី៦ របស់អ្នករាយការណ៍ពិសេសបានធ្វើជួនគ្នានឹងការប្រារព្ធទិវាសិទ្ធិមនុស្ស នៅថ្ងៃ ១០ ធ្នូ ២០១១ ដែលគាត់បានចូលរួមក្នុងការដើរព្យុះហយាត្រា និងការប្រមូលផ្តុំមួយ ដែលរៀបចំដោយសង្គមស៊ីវិល ដើម្បីកត់សំគាល់ទិវានេះ។ នៅក្នុងសេចក្តីថ្លែងរបស់គាត់ ទៅកាន់អ្នកចូលរួមទិវានេះ គាត់បានគូសបញ្ជាក់ពីពីការងាររបស់គាត់នៅក្នុងប្រទេសនេះ ដើម្បីការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅក្នុងប្រទេសនេះ។ ក្នុងកំឡុងពេល និងក្រោយពេលនៃការប្រមូលផ្តុំ គាត់បានស្វាគមន៍ឱកាសទាក់ទង

ជាមួយប្រជាពលរដ្ឋកម្ពុជាមួយចំនួនធំ និងស្តាប់ពីកង្វល់របស់ពួកគេ ជុំវិញស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសនេះ។ គាត់ក៏បានធ្វើទស្សនៈកិច្ច និងធ្វើសេចក្តីថ្លែងនៅក្នុងទិវាសិទ្ធិមនុស្ស ដែលរៀបចំដោយសហគមន៍បឹងកក់នៃរាជធានីភ្នំពេញ។ គាត់ត្រូវបានលើកទឹកចិត្តដោយការសំរេចចិត្តរបស់ស្ត្រីរស់នៅក្នុងសហគមន៍នេះ ដើម្បីការពារសិទ្ធិរបស់ពួកគេតាមលក្ខណៈសន្តិវិធី។

១៣. នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១១ អ្នករាយការណ៍ពិសេស បានធ្វើសេចក្តីថ្លែងដ៏សំខាន់មួយ នៅក្នុងឱកាសនៃការសម្ពោធការបោះពុម្ពផ្សាយថ្មីមួយ ជាភាសាខ្មែរ និងអង់គ្លេសរបស់ការិយាល័យOHCHR "គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស"។ ការអនុវត្តក្របខ័ណ្ឌ "ការពារ គោរព និងដោះស្រាយ" របស់អង្គការសហប្រជាជាតិដែលជាការបកប្រែលើកទី១នៃគោលការណ៍ណែនាំ ទៅជាភាសាមួយដែលមិនមែនជាភាសាសហប្រជាជាតិ។ នៅក្នុងឱកាសនោះ គាត់បានស្វាគមន៍អ្នកតំណាងចូលរួមប្រហែល ១០០នាក់មកពីរដ្ឋាភិបាល រួមមាន ក្រសួងបរិស្ថាន ក្រសួងយុត្តិធម៌ សមាជិកសភា ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិកមកពីអង្គការក្រៅរដ្ឋាភិបាល/សង្គមស៊ីវិល ផ្នែកឯកជន និងសមាគមធុរកិច្ច សមាគមវិជ្ជាជីវៈ ព្រមទាំងអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ផងដែរ។ អ្នករាយការណ៍ពិសេស បានសង្កត់ធ្ងន់ថា គន្លងសព្វថ្ងៃរបស់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម នឹងមិនស្ថិតស្ថេរទេ ប្រសិនបើការអភិវឌ្ឍន៍នេះ មិនឈរលើមូលដ្ឋានដាក់បញ្ចូល និងរៀបចំផែនការឱ្យបានល្អ ហើយគាត់បានគូសបញ្ជាក់ថា ការអនុវត្តន៍ធុរកិច្ច ត្រូវតែធ្វើដោយមានការទទួលខុសត្រូវ និងរួមជាមួយការវាយតំលៃដ៏ត្រឹមត្រូវ និងការត្រួតពិនិត្យដ៏សមរម្យលើសិទ្ធិមនុស្ស។ គាត់បានកត់សម្គាល់ថា គោលការណ៍ណែនាំនេះ ផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់រាជរដ្ឋាភិបាល សហគ្រាសធុរកិច្ច សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ អនុវត្តតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។

១៤. ក្នុងឱកាសខួបលើកទី២០ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ២០១១ អ្នករាយការណ៍ពិសេស បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដែលគាត់បានកត់សម្គាល់ថា ការរីកចំរើនក្នុងសន្តិភាព និងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រនេះ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយ ក៏ប៉ុន្តែយោងទៅតាមបញ្ហាដែលកំពុងកើតមាន ជាពិសេសជាមួយប្រជាធិបតេយ្យពហុនិយម ឯករាជ្យភាពតុលាការ និងនិទណ្ឌភាព។ គាត់ក៏បានចូលរួមប្រជុំចំនួនពីរលើក ទីមួយនៅទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១១ និងលើកទី២ នៅសកលវិទ្យាល័យកាលីហ្វ័រញ៉ាប៊ឺកខឺលី កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១១ ហើយគាត់បានចែករំលែកទស្សនៈយល់ឃើញរបស់គាត់ពីការវិវត្តន៍នៃស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩១ មក។

## II. ការតាមដានការអនុវត្តអនុសាសន៍ក្នុងរបាយការណ៍មុនៗ

១៥. កំឡុងពេលបេសកកម្មរបស់គាត់មកកម្ពុជា អ្នករាយការណ៍ពិសេសបានស្វែងរកព័ត៌មានអំពីការរីកចំរើន ដែលបានធ្វើ ដើម្បីអនុវត្តន៍អនុសាសន៍ដែលគាត់បានធ្វើនៅក្នុងរបាយការណ៍មុនៗពីប្រព័ន្ធតុលាការ និងសភា។

១៦. អ្នករាយការណ៍ពិសេស មានសេចក្តីសោមនស្សដោយកត់សំគាល់ថា រដ្ឋាភិបាលបានឆ្លើយតបជាវិជ្ជមាន ដើម្បីបង្កើនល្បឿនកម្មវិធីច្បាប់របស់ខ្លួន ដែលត្រូវរៀបចំដើម្បីអនុវត្តន៍ ជាអាទិ៍ អនុសាសន៍ជាគន្លឹះ ដែលគាត់បានធ្វើពាក់ព័ន្ធទៅនឹងប្រព័ន្ធតុលាការជាដើម។ រដ្ឋាភិបាល បានចង្អុលបង្ហាញថា អនុសាសន៍ ដែលធ្វើនៅក្នុងរបាយការណ៍មុនៗ ស្តីពីប្រព័ន្ធតុលាការ ត្រូវបានកំពុងអនុវត្ត ឬក៏ស្ថិតនៅក្នុងដំណើរការនៃការរៀបចំផែនការសំរាប់អនុវត្ត។ ជាឧទាហរណ៍ គាត់ត្រូវបានលើកទឹកចិត្តដោយការគូសបញ្ជាក់ថា ច្បាប់រៀបចំអង្គការតុលាការ ដែលពន្យាពេលយ៉ាងយូរនោះ នៅទីបំផុត ត្រូវបានវិវត្តទៅមុខហើយ។ គួរឱ្យកត់សម្គាល់ថា ក្រុមការងារអន្តរក្រសួងមួយ ត្រូវបានបង្កើតឡើងសំរាប់កិច្ចការនេះ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនទាន់បានឆ្លើយតបនៅឡើយ នូវសំណើររបស់គាត់ ឱ្យធ្វើការប្តេជ្ញាចិត្តកំណត់ពីពេលវេលា ឬផែនការសកម្មភាពច្បាស់លាស់មួយ ដើម្បីអនុវត្តន៍អនុសាសន៍គន្លឹះនេះ។

១៧. ទាក់ទងនឹងកំណែទម្រង់សភា រាជរដ្ឋាភិបាលបានចង្អុលបង្ហាញថា អនុសាសន៍មុនៗ របស់អ្នករាយការណ៍ពិសេស ត្រូវបានយកមកពិចារណាយ៉ាងយកចិត្តទុកដាក់ ហើយចំណុចជាច្រើននៃអនុសាសន៍នេះ នឹងទៅជាផ្នែកមួយ នៃដំណើរការអនុវត្តអនុសាសន៍នៃដំណើរការពិនិត្យទៀងទាត់ជាសកល(UPR) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនទាន់បានឆ្លើយតបទៅនឹងសំណើរបស់អ្នករាយការណ៍ពិសេស ឱ្យមានចម្លើយច្បាស់លាស់បន្ថែមទៀតឡើយ ឬពីពេលវេលា ឬផែនការសកម្មភាព ដើម្បីអនុវត្តអនុសាសន៍ជាគន្លឹះរបស់គាត់។

## III. ទំនាក់ទំនងដែលបានផ្ញើជូនរដ្ឋាភិបាល

១៨. អ្នករាយការណ៍ពិសេស បានថ្លែងពីទំនាក់ទំនងមួយចំនួនដែលបានផ្ញើជូនរាជរដ្ឋាភិបាល កំឡុងពេលធ្វើរបាយការណ៍ អំពីករណីជាក់លាក់នានាដែលជាកង្វល់សិទ្ធិមនុស្ស រួមមានការអំពាវនាវជាបន្ទាន់រួមគ្នាមួយ ជាមួយនឹងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យថាជាផ្នែកមួយនៃសិទ្ធិមានជីវភាពរស់នៅសមរម្យ និងស្តីពីសិទ្ធិមិនរើសអើងក្នុងសិទ្ធិលំនៅដ្ឋាន។ គាត់ក៏បានផ្ញើទំនាក់ទំនងមួយទៀតជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពនៃអ្នកការពារសិទ្ធិមនុស្សនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ដែលពាក់ព័ន្ធនឹងការបំផ្លាញចោលផ្ទះចំនួន៥ខ្នង នៅក្នុងតំបន់បឹងកក់ (ក្រុងភ្នំពេញ)។

១៩. លិខិតអះអាងរួមមួយត្រូវបានផ្ញើជូន នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ ស្តីពីការបណ្តេញចេញដោយបង្ខំដែលមានចំនួនប្រហែល៣០០គ្រួសារ មកពីបុរីកីឡា ក្រុងភ្នំពេញ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២ ដែលក្នុងការបណ្តេញនេះ ត្រូវបានអះអាងថាមានប្រើចំពាមកៅស៊ូ ឧស្ម័នបង្ហូរទឹកភ្នែក និងដុំថ្ម ហើយជាលទ្ធផលមានសមាជិកសហគមន៍មួយចំនួនត្រូវបានឃុំខ្លួនតាមទំនើងចិត្ត។ លិខិតជូនដំណឹងរួមនេះ ត្រូវបានធ្វើរួមគ្នាដោយអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យថាជាផ្នែកមួយនៃសិទ្ធិមានជីវភាពរស់នៅសមរម្យ និងស្តីពីសិទ្ធិមិនរើសអើងក្នុងសិទ្ធិលំនៅដ្ឋាន អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធីនិងសមាគម អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពនៃគំនិតនិងការបញ្ចេញមតិ និងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិរបស់បុគ្គលគ្រប់រូប ពីការទទួលបានស្តង់ដារខ្ពស់បំផុតដែលអាចទទួលបាននៃសុខភាពផ្លូវកាយ និងផ្លូវចិត្ត។

២០. លិខិតសុំចាត់វិធានការបន្ទាន់បន្ថែមមួយទៀតត្រូវបានផ្ញើជូនរាជរដ្ឋាភិបាលនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២ ពាក់ព័ន្ធនឹងរឿងគ្រួសារនានានៅក្នុងជំលោះរបស់សហគមន៍បឹងកក់ ដោយផ្អែកលើព័ត៌មានដែលទទួលបានអំពីការចាប់ខ្លួន និងការកាត់ទោសអ្នកតវ៉ា១៣នាក់ មកពី៨គ្រួសារដែលទទួលរងពីវិវាទនេះ និងការចាប់ខ្លួនអ្នកតំណាងពីរនាក់ជាបន្ទាប់មកទៀតនៃសហគមន៍បឹងកក់ ហើយក្រោយមក ចាប់ខ្លួនព្រះសង្ឃមួយអង្គដែលលេចធ្លោនិងជាអ្នកការពារសិទ្ធិមនុស្ស ដែលព្រះអង្គបានចូលរួមតវ៉ាដោយសន្តិវិធីក្នុងការគាំទ្រដល់សហគមន៍បឹងកក់។ លិខិតជូនដំណឹងនេះ ត្រូវបានធ្វើរួមគ្នាដោយប្រធានអ្នករាយការណ៍របស់ក្រុមការងារស្តីពីការឃុំខ្លួនតាមទំនើងចិត្ត អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការពារសិទ្ធិសេរីភាពនៃគំនិតនិងការបញ្ចេញមតិ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យថាជាផ្នែកមួយនៃសិទ្ធិមានជីវភាពរស់នៅសមរម្យ និងស្តីពីសិទ្ធិមិនរើសអើងក្នុងសិទ្ធិលំនៅដ្ឋាន អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធីនិងសមាគម អ្នករាយការណ៍ពិសេសស្តីពីសេរីភាពនៃសាសនា និងជំនឿ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស អ្នករាយការណ៍ពិសេសស្តីពីឯករាជ្យភាពចៅក្រមនិងមេធាវី និងអ្នករាយការណ៍ពិសេសស្តីពីអំពើហឹង្សាប្រឆាំងនឹងស្ត្រី មូលហេតុ និងផលវិបាករបស់អំពើហឹង្សា។

២១. នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២ អ្នករាយការណ៍ពិសេសបានធ្វើរួមគ្នាជាមួយអ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធី និងសមាគម និងអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពនៃអ្នកការពារសិទ្ធិមនុស្ស តាមលិខិតអះអាងរួមគ្នាមួយដែលផ្តោតទៅលើព័ត៌មានស្តីពីការរិតត្បិតចំពោះការទទួលបានសិទ្ធិសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធី សេរីភាពនៃគំនិតនិងការបញ្ចេញមតិ ដែលត្រូវបានរាយការណ៍មកថាបានប្រឈមមុខដោយអ្នករៀបចំ និងអ្នកចូលរួមនៅក្នុងសន្និសិទសង្គមស៊ីវិលអាស៊ាន/វេទិកាប្រជាជនអាស៊ានឆ្នាំ២០១២(ACSC/APF)។ ព្រឹត្តិការណ៍នេះប្រព្រឹត្តទៅនៅថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែមិនា

ឆ្នាំ២០១២ នៅសណ្ឋាគារ Lucky Star ក៏ប៉ុន្តែត្រូវបានទទួលរងនូវការរិតត្បិត និង/ឬការជ្រៀតជ្រែកពីអ្នកគ្រប់គ្រងសណ្ឋាគារទៅតាមសំណើរចោទប្រកាន់របស់រាជរដ្ឋាភិបាល។

២២. បន្ថែមពីលើលិខិតគោរពជូននាយករដ្ឋមន្ត្រីអំពីកំណែទម្រង់នៃការបោះឆ្នោត ដែលបាននិយាយខាងលើ អ្នករាយការណ៍ពិសេសបានផ្ញើលិខិតមួយគោរពជូននាយករដ្ឋមន្ត្រីនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ទាក់ទងនឹងការពិភាក្សារវាងសហគមន៍បឹងកក់ដែលនៅសេសសល់ និងសាលារាជធានីភ្នំពេញ ដែលធ្វើឱ្យកើតជាអនុក្រឹត្យលេខ១៨៣ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ ស្តីពីការកាត់តំរឹមទំហំដីអភិវឌ្ឍន៍បឹងកក់ ដោយសំរេចផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីទៅសហគមន៍សំរាប់រស់នៅលើផ្ទៃដីចំនួន ១២,៤៤ ហិកតា។ អនុក្រិត្យនេះត្រូវបានចាត់ទុកថាជាជំហានវិជ្ជមានមួយតាមទិសដៅត្រឹមត្រូវ អ្នករាយការណ៍ពិសេសបានសំដែងក្តីសង្ឃឹមថា ដំណើរការពិគ្រោះយោបល់ស្រដៀងគ្នានេះ នឹងគួរត្រូវយកមកអនុវត្ត ពាក់ព័ន្ធនឹងករណីនៃវិវាទដីធ្លីដទៃទៀតនៅក្នុងប្រទេសនេះ។ នៅក្នុងលិខិតដដែលនោះ អ្នករាយការណ៍ពិសេស បានសំដែងក្តីសង្ឃឹមថា ការស្នើសុំឱ្យអ្នកមានចំណែកដែលពាក់ព័ន្ធចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវយកទៅពិចារណា មុនសេចក្តីព្រាងច្បាប់នេះត្រូវបានបញ្ជូនទៅសភាដើម្បីអនុម័ត។

២៣. បន្ទាប់ពីការព្យួរ និងការព្រមានដែលធ្វើចំពោះអង្គការក្រៅរដ្ឋាភិបាលចំនួន៣ ដែលធ្វើការការពារសិទ្ធិមនុស្សក្នុងរឿងដីធ្លី និងផ្ទះសម្បែង អ្នករាយការណ៍ពិសេសបានផ្ញើលិខិតមួយគោរពជូននាយករដ្ឋមន្ត្រី នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ដោយសំដែងពីការព្រួយបារម្ភរបស់គាត់អំពីការព្យួរនេះ ហើយស្នើសុំឲ្យរដ្ឋាភិបាល ចែករំលែកព័ត៌មានអំពីបញ្ហានេះ។ អ្នករាយការណ៍ពិសេសបានទទួល ចម្លើយមួយពីរដ្ឋាភិបាល កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ដោយធ្វើការបំភ្លឺពីស្ថានភាព និងការយល់ឃើញរបស់រដ្ឋាភិបាល ដែលពាក់ព័ន្ធទៅនឹងអង្គការទាំងបីនោះ។

## IV. ការវិវត្តន៍ថ្មីៗ ក្នុងវិស័យសិទ្ធិមនុស្ស

២៤. អ្នករាយការណ៍ពិសេសបានបន្តឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សជាទូទៅនៅក្នុងប្រទេសនេះ ហើយគូសបញ្ជាក់ពីការវិវត្តន៍សំខាន់ៗមួយចំនួននៅក្នុងបញ្ហានេះ ដូចខាងក្រោម។

### ក. សិទ្ធិដីធ្លី និងផ្ទះសម្បែង

២៥. ជំលោះដីធ្លី និងការបណ្តេញចេញដោយបង្ខំ នៅតែបន្តដោយគ្មានស្រាកស្រាន្តនៅក្នុងប្រទេសកម្ពុជា ហើយបង្ហាញពីការប្រើកំលាំង ដោយអាជ្ញាធរ និងសហគ្រាសធុរកិច្ច។ បញ្ហានេះបានឈានទៅរកការប៉ះទង្គិចគ្នាដោយហឹង្សាជាមួយសហគមន៍នៅក្នុងកំឡុងពេលធ្វើរបាយការណ៍នេះ។ ករណីបឹងកក់ដែលមាន

ការចាប់អារម្មណ៍ខ្ពស់ ឃើញថាមានការវិវត្តន៍គួរឱ្យកត់សំគាល់ តាមរយៈការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីទៅឱ្យប្រជាជនជាង៦០០គ្រួសារ ទោះជាយ៉ាងណាក៏ដោយ អ្នកទាំងឡាយដែលត្រូវផាត់ចេញពីកំពោងនេះ ត្រូវប្រឈមមុខនឹងការបណ្តេញចេញដោយហឹង្សា កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ នៅពេលដែល ក្នុងភូមិ២២ សាលារាជធានីភ្នំពេញ និងក្រុមហ៊ុន Shukaku Inc ដោយមានការគាំទ្រពីកងរាជអាវុធហត្ថ បានអនុវត្តការរុះរើផ្ទះ ចំនួន៥ខ្នង (ដែលជឿថាមានចំនួន៨គ្រួសារសរុប) ត្រូវបានរាយការណ៍ថា ដោយគ្មានការចរចាពីសំណាងត្រូវបានព្រមព្រៀងគ្នានោះទេ។ គ្រួសារទាំងនេះ មិនត្រូវបានប្រាប់ឱ្យដឹងជាមុន ពីការបណ្តេញចេញនេះទេ ហើយគ្រួសារជាច្រើនបានបាត់បង់ទ្រព្យសម្បត្តិរបស់ពួកគេ ក្នុងពេលនៃការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេ។ មានការតវ៉ា និងបាតុកម្មជាច្រើន ដោយសហគមន៍បឹងកក់ ដឹកនាំដោយស្រីៗ ហើយជាការតបតមានការប្រើប្រាស់កំលាំងច្រើនលើសលុបពីអាជ្ញាធរ។ ករណីបឹងកក់គឺជានិមិត្តសញ្ញានៃការអស់សង្ឃឹម ដែលថាសហគមន៍នានានៅទូទាំងព្រះរាជាណាចក្រនេះ ប្រឈមមុខនៅក្នុងការដោះស្រាយជំលោះដីធ្លីរបស់ពួកគេ ហើយជាលទ្ធផល នាំឱ្យមានកោលាហលក្នុងស្រុក។

២៦. បញ្ហាប្រឈមនានានៅតែបន្តក្នុងការអនុវត្តក្របខ័ណ្ឌច្បាប់ជាតិស្តីពីដីធ្លីនិងផ្ទះសម្បែង។ នៅដើមឆ្នាំ ២០១០ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី បានចេញសេចក្តីព្រាងមួយស្តីពីគោលនយោបាយផ្ទះសម្បែងដែលទទួលស្គាល់សិទ្ធិមានលំនៅដ្ឋានសមរម្យ។ គោលនយោបាយនេះ មិនទាន់ត្រូវបានអនុម័តនៅឡើយទេពីគណៈរដ្ឋមន្ត្រី។ សេចក្តីព្រាងច្បាប់ពីរបន្ថែមទៀត គឺអនុក្រឹត្យស្តីពីនគររូបនីយកម្ម (ដែលស្នើដោយក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់) និងច្បាប់មួយទៀតស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្ម (ដែលស្នើដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ត្រូវបានផ្សព្វផ្សាយ ក៏ប៉ុន្តែវានៅតែត្រូវបានឃើញថា ត្រូវធ្វើយ៉ាងណាឱ្យច្បាប់ទាំងពីរនេះស៊ីគ្នាជាមួយស្ថាបត្យកម្មជាតិដែលមានរួចហើយ និងកាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

២៧. ការបណ្តេញចេញដោយបង្ខំនៃអ្នកភូមិនៅសហគមន៍បុរីកីឡា ក្នុងសង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១២ គឺការព្រួយបារម្ភជាពិសេស និងផលប៉ះពាល់ទៅលើសហគមន៍នេះ។ អ្នករាយការណ៍ពិសេសបានជ្រាបថា ការបណ្តេញចេញដោយបង្ខំនេះ មានលក្ខណៈជាការបំផ្លាញចោលលំនៅដ្ឋានប្រហែលជា៣០០ខ្នង ហើយជាលទ្ធផលនាំឱ្យមានការប៉ះទង្គិចដោយហឹង្សា រវាងកំលាំងចំរុះ មានដូចជា ប៉ូលីសប្រដាប់អាវុធ កងរាជអាវុធហត្ថ និងអាជ្ញាធរខណ្ឌ បុគ្គលិកក្រុមហ៊ុនផាន អ៊ីមិចជាមួយនឹងអ្នករស់នៅសហគមន៍បុរីកីឡា។ បន្ថែមលើការប៉ះទង្គិចខាងផ្លូវចិត្ត និងការរងរបួសចំពោះអ្នកទាំងឡាយដែលមានវត្តមានក្នុងអំពើហឹង្សានោះ រួមទាំងមន្ត្រីមួយចំនួនផង និងបញ្ហាមនុស្សធម៌ជាបន្ទាន់ដែលកំពុងប្រឈមមុខចំពោះក្រុមគ្រួសារដែលត្រូវបានបណ្តេញចេញ អ្នករាយការណ៍ពិសេសព្រួយបារម្ភអំពីបញ្ហានីតិវិធី និងផ្លូវច្បាប់ដែលទាក់ទងទៅនឹងការបណ្តេញចេញនេះ ដែលត្រូវរាយការណ៍មកថា មានជាប់ទាក់ទងនឹងកង្វះខាតក្នុងការអនុវត្តន៍ផែនការអភិវឌ្ឍន៍នៅនឹងកន្លែង ដែលផ្តល់ឱ្យតាមកិច្ចព្រមព្រៀង

ឆ្នាំ២០០៤ រវាងរាជរដ្ឋាភិបាល និងក្រុមហ៊ុនផាន អ៊ីមិច។ សំខាន់បំផុតនោះ អ្នករាយការណ៍ពិសេសព្រួយបារម្ភថា ព្រឹត្តិការណ៍ដែលបានឡើងដល់កំរិតខ្ពស់បំផុតនៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១២ បានបង្ហាញពីភាពគ្មានសមត្ថភាពរបស់អ្នកទាំងឡាយដែលពាក់ព័ន្ធនឹងការដោះស្រាយជំលោះដោយសន្តិវិធី និងបានបង្ហាញពីការបែរមកប្រើកំលាំងដោយអាជ្ញាធរ ក៏ដូចជាសហគមន៍នានា។

២៨. លើសពីនេះទៅទៀត ឧប្បត្តិវហេតុនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ នៅពេលស្រ្តី២៤នាក់ និងក្មេង៦នាក់ មកពីសហគមន៍បុរីកីឡា ត្រូវបានចាប់ខ្លួន កំឡុងពេលតវ៉ាដោយសន្តិវិធីមួយ នៅខាងក្រៅសាលារាជធានីភ្នំពេញ ហើយបន្ទាប់មក ត្រូវបានឃុំនៅមណ្ឌលសង្គមកិច្ចក្រុងភ្នំពេញ (មណ្ឌលព្រៃស្តី) គឺជាឧទាហរណ៍យ៉ាងអាក្រក់មួយនៃការធ្វើបាបជាបន្តដល់បុគ្គល និងសហគមន៍ ដែលមានបំណងទាមទារសិទ្ធិដីធ្លីរបស់ពួកគេ។ ទោះបីជាករណីទាំងអស់ មិនមែនជាករណីដែលត្រូវចាប់អារម្មណ៍ខ្ពស់ អ្នករាយការណ៍ពិសេសត្រូវបានផ្តល់ព័ត៌មានជូនយ៉ាងទៀងទាត់ពីករណីនៃការធ្វើឱ្យទៅជាបទល្មើសព្រហ្មទណ្ឌ ការឃាយឃីនិងការបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្ស សហគមន៍ និងមន្ត្រីដែលពាក់ព័ន្ធនៅក្នុងជំលោះដីធ្លីទូទាំងព្រះរាជាណាចក្រនេះ។

២៩. នៅក្នុងលក្ខខណ្ឌមានលំនៅដ្ឋាន និងជីវភាពរស់នៅសមរម្យ ការបណ្តេញចេញនៅបុរីកីឡា បង្កើតស្ថានភាពលំនៅដ្ឋានមិនស្ថិតស្ថេរ និងភាពគ្មានផ្ទះសំបែងចំពោះមនុស្សជាច្រើន។ សហគមន៍នានាដែលរស់នៅកន្លែងបោះទីតាំងថ្មីពីមុនការបណ្តេញចេញ ហើយការបោះទីតាំងថ្មីនោះរាយការណ៍មកថា ពុំមានលំនៅដ្ឋានសមរម្យ បញ្ហាប្រឈមនានាក្នុងការទទួលបានហេត្ថារចនាសម្ព័ន្ធសុខភាព និងអប់រំ ភាពធ្ងះធ្ងាយដល់រចនាសម្ព័ន្ធគ្រួសារ ហើយគួរឱ្យកត់សំគាល់បំផុតនោះគឺការលំបាកជាសារវន្តក្នុងការបង្កើតជំរើសផ្សេងៗសំរាប់ជីវភាពរស់នៅ។ សហគមន៍ជាច្រើន រស់នៅទាំងអស់សង្ឃឹមនៅលើកន្លែងបោះទីតាំងថ្មីដែលមិនអាចរស់នៅបានកន្លងមក មានចម្ងាយឆ្ងាយពីទីក្រុងដែលមិនត្រូវបានរៀបចំឱ្យបានសមរម្យ សម្រាប់ការមកដល់នៃគ្រួសារដែលត្រូវបានបណ្តេញចេញ។ កង្វះទឹកស្អាត សេវាអនាម័យ និងជំរកអន់មិនអាចជ្រកផុតពីទឹកភ្លៀង ត្រូវបានរាយការណ៍។ អ្នករាយការណ៍ពិសេសព្រួយបារម្ភថា ការរៀបចំផែនការ និងជំនួយមនុស្សធម៌មិនបានគ្រប់គ្រាន់ រួមជាមួយឱកាសមិនគ្រប់គ្រាន់សម្រាប់ការបង្កើនប្រាក់ចំណូល កំពុងបង្កឲ្យកាន់តែធ្លាក់ខ្លួនក្រថែមទៀត ហើយគំរាមកំហែងដល់ឱកាសរបស់ប្រទេសកម្ពុជា ក្នុងការបង្កើនGDP របស់ខ្លួន។

៣០. សហគមន៍ដែលបានបោះទីតាំងថ្មីក៏ប្រឈមមុខនឹងឧបសគ្គក្នុងការចុះឈ្មោះបោះឆ្នោតផងដែរ។ ជារឿយៗ ការចុះឈ្មោះអ្នកបោះឆ្នោតរបស់បុគ្គលដែលត្រូវបណ្តេញចេញ រក្សានៅលំនៅចាស់ដដែល ដោយមូលហេតុរដ្ឋបាលហើយមិនត្រូវបានផ្ទេរទៅកាន់កន្លែងបោះទីតាំងថ្មីទេ។ សហគមន៍ដែលត្រូវបានបណ្តេញចេញ ហើយបោះទីតាំងថ្មី ត្រូវតែធ្វើដំណើរមកកន្លែងដើមរបស់ពួកគេវិញ ដែលមានចម្ងាយឆ្ងាយ ហើយ

ដូចនេះ ត្រូវចំណាយខ្ពស់ និងជារឿយៗវាមិនចាំបាច់។ ហានិភ័យគឺថា ប្រជាជនជាច្រើននៃអ្នកដែលបានបោះទីតាំងថ្មី នឹងមិនអាចបោះឆ្នោតបានក្នុងការបោះឆ្នោតនាពេលខាងមុខ ដោយសារការលំបាកខាងរដ្ឋបាល និងហរិញ្ញវត្ថុ។

## ខ. សេរីភាពនៃការបញ្ចេញមតិ

៣១. ការគោរពសេរីភាពនៃការបញ្ចេញមតិ យោបល់ និងការប្រមូលផ្តុំ នៅតែជាក្តីព្រួយបារម្ភចម្បងមួយនៃក្តីព្រួយបារម្ភចម្បងនានានៅប្រទេសកម្ពុជា ដូចដែលបានសំដែងឱ្យដឹងដោយដៃគូសន្ទនាជាច្រើន ដែលអ្នករាយការណ៍ពិសេស បានជួបក្នុងកំឡុងពេលនៃបេសកកម្មរបស់គាត់។ អ្នករាយការណ៍ពិសេស បានសង្កត់ធ្ងន់នៅក្នុងរបាយការណ៍មុនៗរបស់គាត់ពីក្តីព្រួយបារម្ភ ដែលទាក់ទងនឹងការដាក់កំហិតដែលមិនអាចធ្វើបានលើសេរីភាពនៃបញ្ចេញមតិ ដែលបណ្តាលមកពីជាអាទិ៍ ការអនុវត្តក្រមព្រហ្មទណ្ឌ ជាពិសេសបទល្មើសទាំងឡាយណាដែលទាក់ទងនឹងបទញុះញង់ និងបរិហារកេរ្តិ៍។ អានុភាពនៃការចោទប្រកាន់ (ឬការគំរាមកំហែងពីការចោទប្រកាន់) ក្រោមក្រមព្រហ្មទណ្ឌ លើប្រជាជនដែលអនុវត្តសិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់ពួកគេ បណ្តាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សេរីភាពនៃការបញ្ចេញមតិ នៅកម្ពុជានេះបើតាមទស្សនៈរបស់អ្នករាយការណ៍ពិសេស។ វាហាក់ដូចជា ប្រជាជនកម្ពុជាជាច្រើនបានអនុវត្តនូវស្វ័យត្រួតពិនិត្យដោយខ្លួនឯង ពីអ្វីដែលពួកគេនិយាយ និងសរសេរ ដែលបង្កដោយភាពភ័យខ្លាចពីការចាប់ខ្លួន និងការឃុំខ្លួន។ ជាពិសេស នេះគឺជាករណីមួយនៅក្នុងការគោរពប្រជាជន ដែលប្រាថ្នាចង់សំដែងនូវទស្សនៈរិះគន់ចំពោះអ្នកទាំងឡាយណាដែលមានអំណាច និងអ្នកទាំងឡាយណាដែលត្រូវបានឃើញថាជាការរិះគន់គំរោងអភិវឌ្ឍន៍ជាតិ ដូចជាការស្តារផ្លូវរថភ្លើងសព្វថ្ងៃនេះជាដើម។

៣២. អ្នករាយការណ៍ពិសេស បានលើកឡើងកាលពីមុន ករណីលោក មឿន សុន អ្នកបុរាណវិទូ ដែលត្រូវបានផ្តន្ទាទោសក្នុងឆ្នាំ២០០៩ ពីបទផ្សាយព័ត៌មានមិនពិត ដោយសារតែលោកបានស្នើថាការដំឡើងប្រព័ន្ធភ្លើងបំភ្លឺថ្មីមួយនៅតាមជញ្ជាំងប្រាសាទអង្គរវត្ត អាចធ្វើអោយអន្តរាយដល់ប្រសាទ។ បណ្តឹងសារទុក្ខចុងក្រោយរបស់លោកសុនទៅតុលាការកំពូលត្រូវបានច្រានចោល កាលពីថ្ងៃ១១ ខែមេសា ឆ្នាំ២០១២ ដោយតុលាការអនុញ្ញាតឲ្យផ្លាស់ប្តូរបទចោទ ពីការផ្សាយព័ត៌មានមិនពិត ទៅជាការញុះញង់ ដោយពុំបានជូនដំណឹងទៅគាត់ និងមេធាវីរបស់គាត់ តាមពេលវេលាមួយសមស្រប ដើម្បីអនុញ្ញាតឲ្យរៀបចំដំណើរការការពារក្តីនោះទេ។

៣៣. បន្ទាប់ពីរបាយការណ៍លើកមុនរបស់អ្នករាយការណ៍ពិសេស រាជរដ្ឋាភិបាលបានបញ្ចេញសេចក្តីទី៣ និងទីបួននៃច្បាប់ស្តីពីសមាគម និងអង្គការក្រៅរដ្ឋាភិបាល។ រដ្ឋាភិបាលបានបង្ហាញពីការចាប់អារម្មណ៍ក្នុងការចែករំលែកសេចក្តីព្រាងច្បាប់នេះ ជាមួយសង្គមស៊ីវិល និងបានកោះប្រជុំពិគ្រោះយោបល់ជាច្រើនលើក

ទៅលើសេចក្តីព្រាងជាបន្តបន្ទាប់ បន្ថែមទៅលើកិច្ចប្រជុំនានាដែលរៀបចំដោយតួអង្គសង្គមស៊ីវិល។ អ្នករាយការណ៍ពិសេស សូមស្វាគមន៍ពីសុឆន្ទៈរបស់រដ្ឋាភិបាល ក្នុងការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលអំពីច្បាប់នេះ។ កង្វល់សិទ្ធិមនុស្សសំខាន់ៗ នៅតែសេសសល់នៅក្នុងសេចក្តីព្រាងច្បាប់ថ្មី។ កាលពីចុងខែធ្នូ ឆ្នាំ២០១១ នាយករដ្ឋមន្ត្រីបានប្រកាសថា ការពិគ្រោះយោបល់លើច្បាប់ស្តីពីសមាគម និងអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវបន្ត ទោះបីជាប្រសាសន៍នេះ មានន័យថា ការអនុម័តច្បាប់នេះ នឹងត្រូវពន្យាពេលជាច្រើនឆ្នាំទៀតក៏ដោយ។ អ្នករាយការណ៍ពិសេសសូមអបអរសាទរចំពោះយុទ្ធសាស្ត្រនេះដែលសំរេចដោយនាយករដ្ឋមន្ត្រី ពីច្បាប់ដ៏រសើបមួយនេះ។

## គ. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៣៤. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅតែបន្តធ្វើឲ្យមានការវិវត្តន៍ជានិរន្ត ឆ្ពោះទៅបញ្ចប់ការជំនុំជម្រះរបស់ខ្លួន ក្នុងកំឡុងធ្វើរបាយការណ៍នេះ។

៣៥. សាលដីកានៃអង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង០០១ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានឈានដល់ការបិទដំណើរការនីតិវិធីប្រឆាំងនឹងកាំង ហ្កេក អ៊ាវ ហៅឌុច អតីតប្រធានមន្ទីរស២១ (ទួលស្លែង)។ អង្គជំនុំជម្រះបានបង្កើនទោស ឌុច ពីការដាក់ពន្ធនាគារ៣៥ឆ្នាំ ទៅការដាក់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះសាលាដំបូងចាប់ផ្តើមជំនុំជម្រះអង្គសេចក្តីលើសំណុំរឿង០០២ ប្រឆាំងនឹងសហជនជាប់ចោទបីនាក់ គឺនួន ជា អៀង សារី និងខៀវ សំផន។ សហជនជាប់ចោទទីបួនគឺ អ្នកស្រីអៀង ធារិទ្ធិ (ដែលត្រូវអះអាងថាជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចក្រោមរបបខ្មែរក្រហម) មានសុខភាពមិនសូវល្អ មិនអាចចូលរួមសវនាការបាន។

៣៦. ទោះបីជាមានការរីកចំរើនក្នុងសំណុំរឿង០០២ និងការបញ្ចប់សវនាការសំណុំរឿង០០១ ក៏ដោយដំណើរការក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានតាមបន្លាចដោយការចោទប្រកាន់ពីបរាជ័យក្នុងការស៊ើបអង្កេតឲ្យបានត្រឹមត្រូវលើសំណុំរឿង០០៣ និងសំណុំរឿង០០៤។ ចាប់តាំងពីខែតុលា ឆ្នាំ២០១១ មក សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំនួនពីររូប បានលាលែងពីតំណែងជាបន្តបន្ទាប់ ដោយសំអាងថា មានការជ្រៀតជ្រែកនយោបាយត្រូវបានមើលឃើញជាចំហ និងឧបសគ្គក្នុងការស៊ើបអង្កេត។ នៅក្នុងករណីលាលែងចុងក្រោយ ការចោទប្រកាន់បីការរាំងស្ទះនេះបានកើតឡើង តាមរយៈការបដិសេធមួយផ្នែក ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការទទួលស្គាល់ការតែងតាំងចៅក្រមនោះ ទោះបីជាអង្គការសហប្រជាជាតិ នៅតែបញ្ជាក់ថា ឧត្តមក្រុមប្រឹក្សានេះមានកាតព្វកិច្ចត្រូវតែធ្វើការតែងតាំងក៏ដោយ។ អ្នករាយការណ៍ពិសេស មានការព្រួយបារម្ភអំពីការវិវត្តទាំងនេះ ដែលធ្វើឲ្យខូចសមត្ថភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការធ្វើជាគំរូវិជ្ជមានមួយ សំរាប់ប្រព័ន្ធតុលាការក្នុងស្រុក និងដើម្បីធ្វើឲ្យ

ឃើញពីភាពឯករាជ្យ និងភាពមិនលំអៀងចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងកំឡុងរបបខ្មែរក្រហម នៅកម្ពុជា។ អ្នករាយការណ៍ពិសេសបានទទូចឲ្យរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ចាត់វិធានការជាបន្ទាន់ ដើម្បីដោះស្រាយជំលោះណាមួយ ស្តីពីបញ្ហានានានៅជុំវិញសំណុំរឿងទាំងនេះ ហើយធានាឲ្យបើកការស៊ើបអង្កេតភ្លាម និងត្រឹមត្រូវ ព្រមទាំងគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនសង្ស័យ និងសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណង។

## ឃ. អ្នកការពារសិទ្ធិមនុស្ស

៣៧. អ្នកការពារសិទ្ធិមនុស្សជាច្រើន តំណាងសង្គមស៊ីវិល និងអ្នកកាសែតនៅកម្ពុជានៅតែបន្តប្រឈមមុខនឹងការយាយី ការបំភិតបំភ័យ និងការគំរាមកំហែងពីបណ្តឹងបរិហារកេរ្តិ៍ ឬបទញុះញុង។ ការគំរាមកំហែងដែលប្រឈមមុខចំពោះបុគ្គលទាំងនេះ បានឈានទៅរករបត់ធ្ងន់ធ្ងរមួយ ឲ្យកាន់តែអាក្រក់ ដោយការកើនឡើងនូវការប្រើប្រាស់គ្រាប់ពិតប្រឆាំងនឹងប្រជាជនដែលការពារសិទ្ធិរបស់ពួកគេ និងដែលតវ៉ាប្រឆាំងនឹងការអនុវត្តនិងគោលនយោបាយរដ្ឋាភិបាល។ ចាប់តាំងពីដើមឆ្នាំ២០១២មក យ៉ាងហោចណាស់មានឧប្បត្តិហេតុបួន ដែលបុគ្គលត្រូវបានបាញ់សំលាប់។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ អ្នកភូមិបីរូប ត្រូវរងរបួសយ៉ាងធ្ងន់ធ្ងរនៅពេលកំលាំងសន្តិសុខបានបើកការបាញ់ប្រហារនៅក្នុងជំលោះដីធ្លីសម្បទានមួយ ដែលគ្រប់គ្រងដោយក្រុមហ៊ុនTTY ក្នុងខេត្តក្រចេះ។ នៅថ្ងៃទី២០ ខែកុម្ភៈ ការបាញ់ប្រហារមួយទៅលើក្បួនតវ៉ារបស់កម្មករ នៅទីក្រុងបាវិត បណ្តាលឲ្យស្ត្រីបីនាក់ត្រូវរងរបួសយ៉ាងធ្ងន់ធ្ងរ។ នៅថ្ងៃទី២៦ ខែមេសា អ្នកការពារសិទ្ធិមនុស្ស និងជាសកម្មជនបរិស្ថានគឺលោក ឈុត វុទ្ធី ត្រូវបានបាញ់សំលាប់ នៅខេត្តកោះកុង។ កាលពីថ្មីៗនេះ នៅថ្ងៃទី១៦ ខែឧសភា ក្មេងស្រីម្នាក់អាយុ១៤ឆ្នាំ នៅភូមិក្រមា ត្រូវបានបាញ់សំលាប់ ក្នុងកំឡុងការបណ្តេញចេញដោយហឹង្សាមួយ។ គ្រាប់ពិត ក៏ត្រូវបានយកមកប្រើក្នុងករណីដទៃផ្សេងដែរ តែមិនបានបណ្តាលឲ្យមានរបួសស្នាមនោះទេ។

៣៨. ឧប្បត្តិហេតុទាំងនេះ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើសកម្មភាពនៃអ្នកការពារសិទ្ធិមនុស្ស នៅកម្ពុជា ដោយអ្នកការពារសិទ្ធិមនុស្សជាច្រើនកំពុងតែមានការភ័យខ្លាចចំពោះអាយុជីវិតរបស់ពួកគេ ដោយសារតែលទ្ធផលនៃការបាញ់សំលាប់។ អ្នករាយការណ៍ពិសេស មានការតក់ស្លុត ដោយការបាញ់សំលាប់ទាំងនេះ និងធ្វើអោយពិការ ហើយគាត់កត់សំគាល់ថា គ្មាននរណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយនៃបទឧក្រិដ្ឋទាំងនេះទេ។ គាត់សង្ឃឹមថាការបាញ់សំលាប់ទាំងនេះ ត្រូវបានស៊ើបអង្កេតឲ្យបានត្រឹមត្រូវ និងពេញលេញ ហើយត្រូវនាំខ្លួនឧក្រិដ្ឋជនទៅកាត់ទោស។

## V. តួនាទីរបស់ស្ថាប័នរដ្ឋ ជាពិសេស គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការ លើកស្ទួយ និងការគោរពសិទ្ធិរបស់ប្រជាជន នៅក្នុងបរិបទនៃការបោះឆ្នោត

៣៩.ប្រទេសកម្ពុជាប្រកាន់របបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញដែលប្រតិបត្តិតាមប្រព័ន្ធនយោបាយពហុបក្ស។ សិទ្ធិបោះឆ្នោតត្រូវបានធានាការពារតាមមាត្រា៣៤ នៃរដ្ឋធម្មនុញ្ញ។ ប្រទេសមានសភាពីរ រួមមានព្រឹទ្ធសភា(៦១អសនៈ) និងរដ្ឋសភា(១២៣ អសនៈ)។ នៅព្រឹទ្ធសភា សមាជិក៥៧រូប ត្រូវបានបោះឆ្នោតជ្រើសរើសដោយមិនផ្ទាល់ (តាមរយៈសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់) សំរាប់អាណត្តិប្រាំឆ្នាំ។ សមាជិក០២រូបបន្ថែមទៀត ត្រូវបានជ្រើសតាំងដោយរដ្ឋសភា និងសមាជិក០២រូបទៀត ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ។ ទាំងនេះធ្វើឲ្យការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ (បានធ្វើឡើងក្នុងមួយឆ្នាំមុនការបោះឆ្នោតរដ្ឋសភា) ជាប្រផ្នូលមួយយ៉ាងសំខាន់ចំពោះការបោះឆ្នោតរដ្ឋសភា ដោយសារថា អ្នកទាំងឡាយដែលជាប់ឆ្នោត នឹងចូលរួមបោះឆ្នោតដើម្បីកំណត់សមាជិកព្រឹទ្ធសភា។

៤០. នៅរដ្ឋសភា សមាជិក១២៣រូប ត្រូវបានជ្រើសរើសដោយការបោះឆ្នោតពីប្រព័ន្ធបញ្ជីគណបក្ស ដោយការបែងចែកអសនៈតាមសមាមាត្រ។ សមាជិកសភាមានអាណត្តិបំរើការងារសំរាប់រយៈពេលប្រាំឆ្នាំ។ តាមមាត្រា១០០នៃរដ្ឋធម្មនុញ្ញ ប្រធានរដ្ឋសភា និងអនុប្រធានទាំងពីរ ត្រូវទូលថ្វាយដំបូន្មានដល់ព្រះមហាក្សត្រពីការជ្រើសរើសតស្សរជនណាម្នាក់ពីក្នុងចំណោមគណបក្សដែលឈ្នះ ដើម្បីបង្កើតរាជរដ្ឋាភិបាល។ បន្ទាប់ពីរដ្ឋសភាបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំពោះរដ្ឋាភិបាលរបស់ខ្លួន ព្រះមហាក្សត្រ ទ្រង់ឡាយព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រី។

៤១. តាំងពីការបញ្ចប់ជំលោះកម្ពុជានៅឆ្នាំ១៩៩១ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាទូទៅចំនួនបួនលើកហើយ (ឆ្នាំ១៩៩៣ ១៩៩៨ ២០០៣ និងឆ្នាំ២០០៨) និងការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ពីរលើកហើយ (ឆ្នាំ២០០២ និងឆ្នាំ២០០៧)។

### ក. ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់

៤២. នៅកម្ពុជា មានឃុំ-សង្កាត់ចំនួន១៦៣៣។ ក្រុមប្រឹក្សាឃុំ-សង្កាត់នីមួយៗ មានសមាជិកពី៥ ទៅ១១នាក់ អាស្រ័យលើប្រជារាស្ត្រ និងភូមិសាស្ត្រ។ សមាជិកក្រុមប្រឹក្សា ត្រូវបានបោះឆ្នោតតាមរយៈប្រព័ន្ធសមាមាត្រ ដែលគណបក្សចុះឈ្មោះនៅថ្នាក់ជាតិ អាចប្រកួតប្រជែង តាមរយៈការបង្ហាញបញ្ជីឈ្មោះរបស់បេក្ខជន។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវបានគ្រប់គ្រងដោយច្បាប់វិសោធនកម្ម ស្តីពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ (ខែ០៦ ឆ្នាំ២០០៦)។ ការរៀបចំនិងការប្រព្រឹត្តិទៅនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវទទួលខុសត្រូវដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាអ្នកតែងតាំងគណៈកម្មាធិការរៀបចំការបោះឆ្នោតឃុំ/សង្កាត់ និងខេត្ត បន្ថែមទៅលើគណៈកម្មាធិការមណ្ឌលបោះឆ្នោត ដើម្បី

ត្រួតពិនិត្យការបោះឆ្នោត (មាត្រា៧) រូបមន្តសំរាប់កំណត់ពីការបែងចែកអាសនៈ មានការស្មុគស្មាញបន្តិច ហើយត្រូវបានចែងក្នុងមាត្រា២៣ និង២៧ នៃច្បាប់។

៤៣. ដើម្បីចុះឈ្មោះជាបេក្ខជនម្នាក់ នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ បេក្ខជននោះ ត្រូវមាន (១).សញ្ជាតិខ្មែរពីកំណើត (២).ចេះអាននិងសរសេរភាសាខ្មែរ (៣).បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ/សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត និង(៤).មានអាយុយ៉ាងតិច២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ (មាត្រា៤៥)។ នេះគឺជាការរើសអើងដ៏មានសក្តានុពលប្រឆាំងនឹងពលរដ្ឋកម្ពុជាដែលមិនបានកើតនៅក្នុងប្រទេសកម្ពុជា។ ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបក្ខជនត្រូវតែមានឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ(មាត្រា៤៩)។ គណបក្សនយោបាយរបស់ខ្លួន ត្រូវតែបានចុះបញ្ជី ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ។

៤៤. ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០០៧ បានធ្វើជាសក្ខីកម្មពីការកើនឡើងគួរឲ្យកត់សំគាល់នូវចំនួនបេក្ខជន និងគណបក្សនយោបាយ ដោយប្រកួតប្រជែងជាមួយ គណបក្សនយោបាយចំនួន១២ ដែលបានចុះបញ្ជី និងមានបេក្ខជនចំនួន ១០២២៦៦ នាក់ក្នុង១៦២១ឃុំ/សង្កាត់ទាំងអស់។ ការវិវត្តន៍ជាវិជ្ជមានមួយទៀតពីការបោះឆ្នោតចុងក្រោយនេះ នៅក្នុងការចុះឈ្មោះបេក្ខជនគឺមានការកើនឡើង៥% ក្នុងចំនួនបេក្ខជនជាស្ត្រីបើប្រៀបធៀបទៅនឹងឆ្នាំ២០០២។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលបានធ្វើនៅខែមិថុនា ឆ្នាំ២០១២ គឺជាការបោះឆ្នោតលើកទីបី ចាប់តាំងពីការបញ្ចប់នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីស។ ជាទូទៅ ការបោះឆ្នោតទាំងនេះ ត្រូវបានរៀបចំឡើងក្នុងបរិយាកាសបើកចំហ និងសន្តិវិធីជាង បើប្រៀបធៀបទៅនឹងការបោះឆ្នោតកាលពីមុនៗនៅក្នុងឆ្នាំ២០០៧ និង២០០២។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបង្ហាញពីសមត្ថភាពរបស់ខ្លួន ដើម្បីរៀបចំការបោះឆ្នោតអោយបានល្អតាមលក្ខណៈបច្ចេកទេស។ គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ គ.ជ.ប បានទទួលស្គាល់អ្នកអង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិចំនួន ១៤៨៨៦រូប មកពី៤0អង្គការក្រៅរដ្ឋាភិបាល និងសមាគម និងភ្ញៀវពិសេស ២២រូប មកពីសហភាពអឺរ៉ុប សហព័ន្ធអាលីម៉ង់ និងស្ថានទូតបារាំងនៅភ្នំពេញ។ គ.ជ.ប ក៏បានតែងតាំងអ្នកកាសែតជាតិ និងអន្តរជាតិក្នុងចំនួនសរុប៥១២ មកពីប្រព័ន្ធផ្សព្វផ្សាយចំនួន៥៣ ដើម្បីចូលរួមសង្កេតការណ៍បោះឆ្នោត។ ទោះជាយ៉ាងណាក៏ដោយ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០១២ បានបង្ហាញពីការខ្វះខាតខ្លះនៅក្នុងដំណើរការបោះឆ្នោត ជាពិសេស ទាក់ទងនឹងដំណើរការនៃការចុះឈ្មោះអ្នកបោះឆ្នោត និងអត្តសញ្ញាណអ្នកបោះឆ្នោត។

៤៥. ដើម្បីចុះឈ្មោះជាអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ជននោះត្រូវតែមាន (១).សញ្ជាតិខ្មែរ (២).មានអាយុយ៉ាងតិច១៨ឆ្នាំគិតត្រឹមថ្ងៃបោះឆ្នោត (៣).មានទីលំនៅនៅក្នុងឃុំ/សង្កាត់ដែលខ្លួននឹងទៅបោះឆ្នោត និង(៤).មិនត្រូវបានជាប់ពន្ធនាគារ ឬបញ្ជាក់ថាវិកលចរិកដោយស្ថាប័នមានសមត្ថ

កិច្ចមួយ ឬស្ថិតក្រោមអាណាព្យាបាលភាពនៅថ្ងៃបោះឆ្នោត។ អ្នកបោះឆ្នោតក៏ត្រូវតែចុះឈ្មោះផងដែរ ដើម្បីបោះឆ្នោត និងអាចបង្ហាញភស្តុតាងពីអត្តសញ្ញាណរបស់ខ្លួន ក្នុងពេលបោះឆ្នោត។ ភស្តុតាងនេះ ត្រូវបង្ហាញជារូបថត អាស័យដ្ឋាន សញ្ជាតិ និងថ្ងៃខែឆ្នាំកំណើត។ ភស្តុតាងក៏អាចបញ្ជាក់បាន តាមរយៈការប្រើប្រាស់ឯកសារដែលមានការទទួលស្គាល់រួមបញ្ចូលគ្នា ដូចជាលិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណជាតិ និងសៀវភៅគ្រួសារ ដែលមានបិទរូបថត។ នេះបានសំគាល់ពីការផ្លាស់ប្តូរយ៉ាងធំនៅក្នុងដំណើរការចុះឈ្មោះបោះឆ្នោត ពីការបោះឆ្នោតមុនៗ ដែលបានតំរូវអោយមានតែប័ណ្ណចុះឈ្មោះបោះឆ្នោតប៉ុណ្ណោះ។ ខណៈដែលការផ្លាស់ប្តូរនេះ ត្រូវបានកោតសរសើរ ក៏គួរឲ្យកត់សំគាល់ផងដែរថាប្រព័ន្ធសព្វថ្ងៃ បណ្តាលឲ្យក្រុមប្រជាពលរដ្ឋមួយចំនួន ត្រូវបានដកហូតសិទ្ធិក្នុងការបោះឆ្នោត ឧទាហរណ៍ៈ ប្រជាពលរដ្ឋទាំងឡាយដែលគ្មានអាស័យដ្ឋាន ឬស្នាក់នៅឆ្ងាយពីអាស័យដ្ឋាននៃទីលំនៅជាអចិន្ត្រៃយ៍របស់គេ។ ដៃគូសន្ទនាមួយចំនួនបានផ្តល់យោបល់ថា ភាពស្មុគស្មាញសព្វថ្ងៃនេះ និងប្រព័ន្ធនៃការចុះឈ្មោះអ្នកបោះឆ្នោតដែលមានតំលៃថ្លៃ អាចត្រូវបានជំនួសដោយបញ្ជីស្វ័យប្រវត្តិមួយ ដែលយកចេញពីការចុះបញ្ជីអាត្រានុកូលដ្ឋាន។ សំណើរនេះ សក្តិសមនឹងទទួលបានការស៊ើបអង្កេតដោយយកចិត្តទុកដាក់។

៤៦. តាមទ្រឹស្តី ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ គួរតែបន្ថែមស្រទាប់មួយទៀតនៃធម្មានុរូប ចំពោះលទ្ធិប្រជាធិបតេយ្យដ៏ក្មេងខ្ចីរបស់កម្ពុជា ដោយចែងពីគោលការណ៍ត្រួតពិនិត្យនិងតុល្យភាព ស្តីពីតំណាងសមាមាត្ររបស់គណបក្សនៅកំរិតជាតិ និងការបង្កើនថែមទៀត ដល់មាគ៌ាសំរាប់នយោបាយពហុបក្សកាន់តែរីកសុះសាយ។ បទប្បញ្ញត្តិនៅក្នុងច្បាប់ ទំនងជាមាននិន្នាការគាំទ្រដោយហាមឃាត់ការចូលរួមបោះឆ្នោតពីសមាជិកព្រឹទ្ធសភា រដ្ឋសភា ចៅក្រម ឬមន្ត្រីរាជការ ពីការបោះឆ្នោតទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការអនុវត្តជាក់ស្តែង ការបោះឆ្នោតបានទទួលរងនូវកំហុសមួយចំនួន ដែលកំហុសខ្លះត្រូវបានបញ្ជាក់ដូចខាងក្រោម។

**ខ. ការបោះឆ្នោតជាតិ**

៤៧. មានការបោះឆ្នោតជាតិ ឬសភាតាមកាលកំណត់ចំនួន៤លើកមកហើយ តាំងពីការបញ្ចប់នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ក្នុងឆ្នាំ១៩៩១។ ការបោះឆ្នោតជាតិចុងក្រោយគេ បានរៀបចំឡើងនៅឆ្នាំ២០០៨។ យោងតាមអ្នកឃ្លាំមើលឯករាជ្យ នៅពេលដែលយុទ្ធនាការបោះឆ្នោតឆ្នាំ២០០៨ ជាទូទៅ ត្រូវបានរៀបចំនៅក្នុងបរិយាកាសបើកចំហ និងដោយសន្តិវិធីជាង បើប្រៀបធៀបទៅនឹងការបោះឆ្នោតមុនៗ ការបោះឆ្នោតទាំងនោះ នៅមានចំណុចខ្វះខាតមួយចំនួនទៅតាមស្តង់ដារអន្តរជាតិសម្រាប់ការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ។ ទោះបីជាមានការកែលំអពីបញ្ហាតម្លាភាពយ៉ាងណាក៏ដោយក៏នៅមានកង្វះខាតនៃជំនឿចិត្តពីភាពមិនលំអៀងនៃរដ្ឋបាលបោះឆ្នោត ក្នុងចំណោមដៃគូពាក់ព័ន្ធបោះឆ្នោត។ យុទ្ធនាការ ត្រូវបានកត់សំគាល់ដោយការប្រើប្រាស់ជាប្រចាំ និងយ៉ាងទូលាយនៃធនធានរបស់រដ្ឋ ដោយគណបក្សកាន់

អំណាច និងចោទប្រកាន់ពីការចែកលុយ និងអំណោយ ដោយបេក្ខជននិងមន្ត្រីគណៈបក្សរបស់គណៈបក្សនយោបាយផ្សេងៗ ត្រូវបានរាយការណ៍ថាមានការប្រើយ៉ាងពេញពាស។

៤៨. ច្បាប់សំខាន់សំរាប់គ្រប់គ្រងការបោះឆ្នោតរដ្ឋសភា គឺច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា។ ច្បាប់ដទៃទៀតដែលមានឥទ្ធិពលលើដំណើរការបោះឆ្នោត រួមមាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីគណៈបក្សនយោបាយ ច្បាប់សារព័ត៌មាន ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ច្បាប់ស្តីពីសញ្ជាតិ និងក្រមព្រហ្មទណ្ឌថ្មី។ លើសពីនេះទៅទៀត មានបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសារាចរណែនាំមួយចំនួនរបស់គ.ជ.ប សារាចរណែនាំរួមរវាងក្រសួងមហាផ្ទៃនិងគ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់គ.ជ.ប ព្រមទាំងក្រមសីលធម៌សំរាប់គណៈបក្សនយោបាយ សារព័ត៌មានអ្នកសង្កេតការណ៍ មន្ត្រីបោះឆ្នោត និងក្រមសីលធម៌សំរាប់សមាជិកកងកំលាំងប្រដាប់អាវុធ និងនគរបាល។

៤៩. ច្បាប់ដែលនៅជាធរមាន ជាទូទៅផ្តល់នូវក្របខ័ណ្ឌដែលអាចធ្វើការបាន និងស្របតាមស្តង់ដារអន្តរជាតិយ៉ាងទូលាយ យ៉ាងហោចណាស់ក៏លើអត្ថបទជាក្រដាសដែរ និងបង្កើតស្ថាប័នចាំបាច់សម្រាប់រៀបចំការបោះឆ្នោត។ ក្រមសីលធម៌បញ្ញត្តិពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទាំងឡាយដែលពាក់ព័ន្ធ ក្នុងលក្ខណៈមួយដែលបំពេញចិត្តបានជារួម។ បញ្ហានៅកម្ពុជា ផ្តោតផ្ទួលទាំងស្រុងទៅលើការអនុវត្តមិនគ្រប់គ្រាន់នៃបទប្បញ្ញត្តិច្បាប់ និងកង្វះខាតពិតប្រាកដ ឬកង្វះខាតតាមការមើលឃើញ ពីឯករាជ្យភាពនៃស្ថាប័ន។

៥០. ស្រដៀងគ្នានឹងច្បាប់ស្តីពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ លក្ខខណ្ឌច្បាប់សំរាប់ការចុះឈ្មោះជាបេក្ខជននៅក្នុងការបោះឆ្នោតរដ្ឋសភា លើកឡើងនូវបញ្ហាមួយចំនួន។ យោងតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា បេក្ខជនត្រូវតែបានចុះឈ្មោះជាអ្នកបោះឆ្នោត មានអាយុយ៉ាងតិច២៥ឆ្នាំ មានសញ្ជាតិខ្មែរពីកំណើត មានទីលំនៅក្នុងប្រទេសកម្ពុជា និងត្រូវតែងតាំងដោយគណៈបក្សនយោបាយ។ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា មិនអនុញ្ញាតិអោយមានបេក្ខជនឯករាជ្យ ឈរឈ្មោះនៅក្នុងការបោះឆ្នោតទេ ហើយច្បាប់នេះកំណត់ពីលទ្ធភាព ឈរឈ្មោះជាបេក្ខជន ត្រូវតែជាពលរដ្ឋដែលកើតនៅក្នុងប្រទេសកម្ពុជា ដូច្នេះនេះជាការរារាំងដល់ពលរដ្ឋដែលចូលសញ្ជាតិ។ នៅក្នុងករណីនេះ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា មិនស្របទាំងស្រុងទៅនឹងស្តង់ដារអន្តរជាតិ និងការអនុវត្តល្អៗជាអន្តរជាតិនោះទេ។

**គ. បញ្ហាប្រឈមសំខាន់ៗចំពោះដំណើរការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជា**

៥១. អ្នករាយការណ៍ពិសេសចង់កត់សំគាល់ថា ការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ត្រូវបានបញ្ជាក់ដោយការគោរពបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ មាត្រា២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ដែលកម្ពុជាគឺជារដ្ឋភាគីមួយ) ចែងថា បុគ្គលគ្រប់រូបមានសិទ្ធិចូលរួមក្នុងការប្រព្រឹត្តទៅនៃ

កិច្ចការសាធារណៈនៅក្នុងប្រទេស និងចូលរួមបោះឆ្នោត (និងឲ្យគេបោះឆ្នោតឲ្យ) "នៅក្នុងការបោះឆ្នោតទៀងទាត់ពិតប្រាកដមួយ ដែលត្រូវតែប្រព្រឹត្តទៅជាសកលនិងស្មើភាពគ្នា និងត្រូវតែជាសំងាត់ ដោយធានាការពារនូវការសំដែងមតិដោយសេរី ទៅតាមឆន្ទៈរបស់អ្នកបោះឆ្នោត"។

៥២. មានបញ្ហាមួយចំនួនបានធ្វើឲ្យអ្នករាយការណ៍ពិសេស ចាប់អារម្មណ៍ ក្នុងកំឡុងបេសកកម្មលើកទី៦ របស់គាត់មកកាន់ប្រទេសនេះ។ បញ្ហាមួយក្នុងចំណោមបញ្ហាទាំងនេះ គឺការប្រើប្រាស់ធនធានរបស់រដ្ឋដោយគណៈបក្សនយោបាយ នៅក្នុងកំឡុងយុទ្ធនាការបោះឆ្នោត រួមទាំងពេលម៉ោងបំរើការងាររបស់រដ្ឋាភិបាល យានជំនិះ និងសំភារៈផ្សេងៗ។ អ្នករាយការណ៍ពិសេស បានលើកឡើងពីបញ្ហាទាំងនេះជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលជាក្រសួងទទួលខុសត្រូវជួយដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងការរៀបចំការបោះឆ្នោត។ អ្នករាយការណ៍ពិសេសមានការសប្បាយរីករាយទទួលបានការរ៉ាប់រងពីឯកឧត្តមថា រដ្ឋាភិបាល នឹងធ្វើការណែនាំដល់មន្ត្រីរាជការទាំងអស់ នគរបាល និងបុគ្គលិកយោធា ដែលពួកគេមិនគួរចូលរួមនៅក្នុងសកម្មភាពនយោបាយណាមួយ ខណៈដែលកំពុងធ្វើការនៅក្នុងសមត្ថភាពជាផ្លូវការ ដែលរួមមានការប្រើប្រាស់ធនធានរដ្ឋាភិបាល និងធានាថាអព្យាក្រឹត្យ គឺជាចំណុចខ្ពស់ជាងគេ។

៥៣. គណៈបក្សនយោបាយមួយចំនួន បានរាយការណ៍ពីការគំរាមកំហែង ការបំភិតបំភ័យ និងការយាយី (រួមទាំងដំណើរការក្ដីតាមផ្លូវច្បាប់) ប្រឆាំងនឹងសមាជិក និងបេក្ខជនរបស់ពួកគេ ទាំងនេះគឺជាការចោទប្រកាន់ដែលមានការព្រួយបារម្ភមែនទែន។ អ្នករាយការណ៍ពិសេសយល់ឃើញថា សេរីភាពនៃការបញ្ចេញមតិ និងការប្រមូលផ្ដុំ គឺជាចំណុចស្នូលក្នុងការរៀបចំការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ។ ដើម្បីរៀបចំការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ បរិយាកាសនយោបាយទាំងមូល គួរតែសេរី និងនាំមកនូវការអនុវត្តសិទ្ធិ និងសេរីភាព ដូចបានធានានៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានាដែលកម្ពុជាបានផ្ដល់សច្ចាប័ន។

៥៤. គណៈបក្សនយោបាយនៅកម្ពុជា ពុំត្រូវបានបញ្ញត្តិឲ្យបានទូលំទូលាយទេ ហើយជាទូទៅ ពុំមាននីតិវិធីច្បាស់លាស់តាមប្រជាធិបតេយ្យ សំរាប់ជ្រើសរើសបេក្ខជននោះទេ។ ថ្នាក់ដឹកនាំគណៈបក្សមានអំណាចគ្រប់គ្រងលើបញ្ជីឈ្មោះបេក្ខជន ធ្វើអោយបេក្ខជនកាន់តែស្មោះត្រង់ចំពោះគណៈបក្ស ជាជាងមណ្ឌលបោះឆ្នោតផ្ទាល់របស់ខ្លួន។ ប្រការនេះ ក៏អាចនាំឲ្យមានការដកបេក្ខជនតាមទំនើងចិត្ត ចេញពីបញ្ជីគណបក្ស ដែលនាំឲ្យបាត់បង់អសនៈនៅរដ្ឋសភា។ ការរួមបញ្ចូលគ្នានៃប្រព័ន្ធតំណាងសមាមាត្រនិងប្រព័ន្ធបញ្ជីគណៈបក្ស បណ្ដាលអោយរដ្ឋសភា ក្លាយជាចំណងដែលខ្សោយជាងគេ នៅក្នុងប្រព័ន្ធអភិបាលកិច្ចនៅកម្ពុជា។

៥៥. ទូរទស្សន៍កំពុងតែជំនួសវិទ្យុ មានកាន់តែកើនឡើងនៅកម្ពុជា ថាជាមធ្យោបាយបឋម ដែលតាមរយៈនេះ ធ្វើទំនាក់ទំនងជាមួយនឹងការបោះឆ្នោតជាសាធារណៈ។ ការទទួលបានប្រព័ន្ធផ្សព្វផ្សាយគឺជាកង្វល់ដ៏ធំមួយរបស់គណៈបក្សនយោបាយនានា ក្នុងការបោះឆ្នោតកាលពីលើកមុន។ ក្នុងឆ្នាំ២០០៧ ការទទួលបានប្រព័ន្ធផ្សព្វផ្សាយដោយស្មើភាពគ្នា ត្រូវបានផ្តល់អោយគ្រប់គណៈបក្សនយោបាយ ក្នុងការផ្សព្វផ្សាយពីកម្មវិធីនយោបាយរបស់ខ្លួន យ៉ាងហោចណាស់ក៏មួយកម្មវិធី ក្នុងមួយស្ថានីយទូរទស្សន៍ដែរ។ កម្មវិធីព័ត៌មានសមធម៌ ដែលជាគំរោងរួមគ្នារវាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងទូរទស្សន៍ជាតិកម្ពុជា បានផ្តល់ពេលវេលាដល់គ្រប់គណៈបក្សនយោបាយ ឲ្យទទួលបានស្មើគ្នានៅលើប៉ុស្តិ៍ទូរទស្សន៍ជាតិ។ ក្រៅពីនេះទោះជាយ៉ាងណាក៏ដោយ ការទទួលបានប្រព័ន្ធផ្សព្វផ្សាយលើប៉ុស្តិ៍ទូរទស្សន៍ផ្សេងទៀត ដោយគណៈបក្សនយោបាយនានាសំរាប់គោលបំណងធ្វើយុទ្ធនាការនោះ នៅមានកំរិតនៅឡើយ។ ការផ្សព្វផ្សាយពីបេក្ខជនពិភាក្សាគ្នានៅតាមវិទ្យុជាតិ ក៏ត្រូវបានពង្រឹងតាមគោលការណ៍នៃការទទួលបាននូវប្រព័ន្ធផ្សព្វផ្សាយដោយស្មើភាពគ្នា ដល់គ្រប់គណៈបក្សនៅក្នុងសកម្មភាពយុទ្ធនាការរបស់ពួកគេដែរ។

៥៦. បរិយាកាសជុំវិញប្រព័ន្ធផ្សព្វផ្សាយក្នុងការរៀបចំការបោះឆ្នោតរដ្ឋសភាកាលពីលើកមុនក្នុងឆ្នាំ២០០៨ត្រូវបានធ្វើអោយល្អក់កករដោយការបិទស្ថានីយ៍វិទ្យុអង្គររដ្ឋាខេត្តក្រចេះ នៅខែឧសភា ការចាប់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្ន ដោយការចោទប្រកាន់ពីបទបរិហារកេរ្តិ៍លើនិពន្ធនាយកកាសែតមនសិការខ្មែរ គឺលោកដាំ សិទ្ធិ ក្នុងខែមិថុនា និងក្នុងហេតុការណ៍កាន់តែអាក្រក់នោះ គឺឃាតកម្មកាលពីថ្ងៃទី១១ ខែកក្កដាឆ្នាំ២០០៨ នៃអ្នកកាសែតមនសិការខ្មែរ លោកឃឹម សំបូរ និងកូនប្រុសរបស់គាត់គឺខាត់ សារិនភាតា ។ ឧក្រិដ្ឋកម្មនេះ នៅតែមិនទាន់ដោះស្រាយ និងផ្តន្ទាទោសនៅឡើយទេ។ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋដោយគណៈបក្សកាន់អំណាច ក្នុងអំឡុងពេលបោះឆ្នោតកាលពីលើកមុន គឺស្ថិតនៅកំរិតមួយដែលមិនស្របនឹងស្តង់ដារអន្តរជាតិស្តីពីការទទួលបានប្រព័ន្ធផ្សព្វផ្សាយដោយសេរី និងស្មើភាពគ្នា សំរាប់បេក្ខជនប្រកួតប្រជែងបោះឆ្នោតទាំងអស់។ គ្រប់គណៈបក្សប្រឆាំង ទទួលបានប្រព័ន្ធផ្សព្វផ្សាយពីទូរទស្សន៍ជាតិ និងវិទ្យុជាតិ ស្របទៅតាមបទប្បញ្ញត្តិបោះឆ្នោត ព្រមទាំងពេលវេលាដ៏តិចតួចពីស្ថានីយវិទ្យុឯកជនដែលមិនគ្របដណ្តប់ពេញផ្ទៃប្រទេស។ ទោះជាយ៉ាងណាក៏ដោយ នេះទំនងជាមានការខ្វះខាតនៃសមភាពក្នុងការទទួលបានប្រព័ន្ធផ្សព្វផ្សាយ។ ឧទាហរណ៍ យោងតាមរបាយការណ៍ចុងក្រោយរបស់បេសកកម្មឃ្លាំមើលការបោះឆ្នោតរបស់សហភាពអឺរ៉ុប កាលពីការបោះឆ្នោតឆ្នាំ២០០៨ ទូរទស្សន៍ជាតិ បានទុកពេលច្រើនជាង ៩០០នាទី ក្នុងកម្មវិធីព័ត៌មានរបស់ខ្លួន សំរាប់រដ្ឋាភិបាល បើប្រៀបធៀបនឹងរយៈពេល៤នាទីសំរាប់គណៈបក្សប្រឆាំង។ ភាពមានប្រៀបរបស់គណៈបក្សកាន់អំណាច លើការទទួលបានប្រព័ន្ធផ្សព្វផ្សាយ អាចធ្វើឲ្យខូចខាតដល់លទ្ធភាពនៃអ្នកបោះឆ្នោតកម្ពុជា ក្នុងការទទួលបានព័ត៌មានគ្រប់គ្រាន់អំពីគណៈបក្សនយោបាយនានា ដើម្បីធ្វើការសម្រេចចិត្តឲ្យបានត្រឹមត្រូវ។

៥៧. ការមិនយល់យោគគ្នាដែលចេះតែកើនឡើង តាំងពីឆ្នាំ២០០៨ នៃការអនុវត្តសេរីភាពនៃការបញ្ចេញមតិ ក្នុងការរិះគន់អំពើពុករលួយ និទណ្ឌភាព និងការរឹបអូសយកដីធ្លី ទំនងជាជះឥទ្ធិពលថែមទៀតដល់បរិយាកាសនយោបាយដែលមានសំរាប់គណៈបក្សប្រឆាំង ក្នុងដំណើរឆ្ពោះទៅរកការបោះឆ្នោតនាពេលខាងមុខ។ នេះត្រូវបានបញ្ជាក់យ៉ាងច្បាស់តាមរយៈការចោទប្រកាន់ពីបទបរិហាកេរ្តិ៍ និងបទញុះញង់ចំពោះសមាជិកគណៈបក្សប្រឆាំង លោកស្រីមួ សុខហួ(ខែមេសា ឆ្នាំ២០០៩) និងលោកហូ វណ្ណ(ខែកក្កដា ឆ្នាំ២០០៩) និងការចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងការញុះញង់ពូជសាសន៍ចំពោះមេដឹកនាំបក្សប្រឆាំងគឺលោកសម រង្ស៊ី។ លោករង្ស៊ី ត្រូវបាន**កាត់ទោសដោយកំបាំងមុខ** នៅខែមករា ឆ្នាំ២០១០ និងត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល២ឆ្នាំ ក្នុងមួយករណី និង១០ឆ្នាំ ក្នុងករណីមួយផ្សេងទៀត ប៉ុន្តែលោកនៅតែរស់នៅនិរទ្ទេសនៅឡើយ។

៥៨. ការអប់រំប្រជាពលរដ្ឋ/អ្នកបោះឆ្នោតប្រកបដោយប្រសិទ្ធភាព គឺជាសមាសធាតុបោះឆ្នោតដ៏សំខាន់១ទៀត ដែលអាចឲ្យអ្នកបោះឆ្នោត អនុវត្តបាននូវសិទ្ធិបោះឆ្នោតរបស់ពួកគេ នៅក្នុងដំណើរការបោះឆ្នោត។ ទោះបីជា គ ជ ប បានចាត់វិធានការសំខាន់ៗ ឆ្ពោះទៅរកការបង្កើនការយល់ដឹងអំពីសិទ្ធិបោះឆ្នោត និងនីតិវិធីផ្លូវការនៃការបោះឆ្នោត ក៏ដោយ (ជាពិសេសតាមរយៈការផ្សព្វផ្សាយប័ណ្ណព័ត៌មានរបស់អ្នកបោះឆ្នោតដែលពន្យល់ពីការចុះឈ្មោះអ្នកបោះឆ្នោតនិងពីដំណើរការនៃការបោះឆ្នោត) ក៏ធាតុពិតដែលថា គ.ជ.ប នៅតែបន្តត្រួតត្រាដោយអ្នកគាំទ្រគណៈបក្សកាន់អំណាចនោះ បានធ្វើឲ្យប៉ះពាល់ដល់ទំនុកចិត្តលើ គ.ជ.ប។ ជាងនេះទៅទៀត ប្រតិបត្តិការរបស់ខ្លួនពីប្រព័ន្ធនៃការចុះឈ្មោះអ្នកបោះឆ្នោត បានបន្សល់ទុកនូវចំណុចខ្វះគួរជាទីពេញចិត្តក្នុងការបោះឆ្នោតកាលពីលើកមុន ដូចជា ភាពចម្រូងចម្រាស់លើការដោះស្រាយពីការចុះឈ្មោះអ្នកបោះឆ្នោត កាលពីអំឡុងពេលបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ២០០៧ (និងជាពិសេស ការលុបឈ្មោះដ៏ច្រើនលើសលប់ពីបញ្ជីអ្នកបោះឆ្នោត) បណ្តាលឲ្យមានការព្រួយបារម្ភនាពេលនោះ ហើយការព្រួយបារម្ភស្រដៀងគ្នានេះ ត្រូវបានលើកឡើងទៀត កាលពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ខែមិថុនា ឆ្នាំ២០១២។

## VI. សេចក្តីសន្និដ្ឋាន

៥៩. ស្ថានភាពសិទ្ធិមនុស្សជារួម មានការរីកចំរើនក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ជាពិសេសមានការអនុម័តច្បាប់សំខាន់ៗមួយចំនួនក្នុងពេលថ្មីៗនេះ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីបំពេញកាតព្វកិច្ចរបស់កម្ពុជា ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលបានផ្តល់សច្ចាប័នដោយកម្ពុជា។ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បានបង្កើតនីតិរដ្ឋ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យថាជាសសរទ្រូងនៃស្ថាបត្យកម្មនយោបាយថ្មីសំរាប់ប្រទេសនេះ។ ដូចនេះ ដំណើរការសន្តិភាព មិនអាចត្រូវបានចាត់ទុកថាបំពេញរួចរាល់នោះទេ ប្រសិនបើស្ថាប័នប្រជាធិបតេយ្យ ដែលត្រូវ

បានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ មិនទាន់អាចបំពេញការងាររបស់ខ្លួនដោយប្រសិទ្ធភាព និងឯករាជ្យភាពទេនោះ។ សហគមន៍ អន្តរជាតិ ក៏មានចំណែក និងការទទួលខុសត្រូវជាពិសេសចំពោះបញ្ហានេះដែរ។

៦០. អ្នករាយការណ៍ពិសេសដឹងច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនិងកែលម្អដំណើរការបោះឆ្នោតនៅក្នុងប្រទេស។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានផ្លូវខ្លះ ដើម្បីឈានទៅសំរេចបាននូវគោលដៅទាំងនេះ ហើយគឺផ្លូវទាំងនោះដែលលោកតំណាងពិសេស ចង់ជួយតាមសមត្ថភាពរបស់គាត់។ គឺនៅក្នុងបរិបទនេះហើយ ដែលគាត់ចង់មានកិច្ចសន្ទនាដ៏មានអត្ថន័យ និង ក្នុងន័យស្ថាបនា ជាមួយរាជរដ្ឋាភិបាល។

៦១. អ្នករាយការណ៍ពិសេសបារម្ភអំពីព័ត៌មានដែលគាត់បានទទួល ទាក់ទងនឹងចំនួនអ្នកចេញទៅបោះឆ្នោតមានកំរិតទាប និន្នាការធ្លាក់ចុះក្នុងការចូលរួមរបស់អ្នកបោះឆ្នោត និងភាពនឿយណាយរបស់អ្នកបោះឆ្នោត និងការអាក់អន់ចិត្តចំពោះប្រព័ន្ធបោះឆ្នោតសព្វថ្ងៃ។ មានហេតុផលមួយចំនួនធំ ថាហេតុអ្វីបានជាបុគ្គលម្នាក់ៗអាចជ្រើសរើសមិនចូលរួមក្នុងដំណើរការបោះឆ្នោត។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីជាច្រើន ប្រជាជនមិនជ្រើសរើសបោះបង់សិទ្ធិបោះឆ្នោតរបស់ពួកគេឡើយ ប៉ុន្តែត្រូវជួបប្រទះនូវការរារាំងជាច្រើនបែបនេះ ទើបពួកគេត្រូវគ្មានសិទ្ធិបោះឆ្នោតបានដោយប្រសិទ្ធភាព។ ដោយការសំដែងចេញនូវការអាក់អន់ចិត្តរបស់ខ្លួនចំពោះប្រព័ន្ធបោះឆ្នោតសព្វថ្ងៃ ពលរដ្ឋខ្មែរម្នាក់បានផ្ញើញត្តិជាលក្ខណៈបុគ្គលមកអ្នករាយការណ៍ពិសេសថា ប្រសិនបើស្ថានភាពបច្ចុប្បន្ននៅតែបន្តនោះ គណៈបក្សកាន់អំណាច នឹងទទួលជ័យជំនះក្នុងការបោះឆ្នោតជារៀងរហូត។ គ្មានសង្ឃឹមទាល់តែសោះ សំរាប់គណៈបក្សនយោបាយដទៃទៀត។

៦២. អ្នករាយការណ៍ពិសេសយល់ឃើញថា ដើម្បីឲ្យដំណើរការបោះឆ្នោតគួរឲ្យជឿជាក់ និងមើលទៅអាចជឿជាក់បាន ហើយទទួលបានធម្មានុរូបចំពោះលទ្ធផលនៃការបោះឆ្នោតទាំងរាជរដ្ឋាភិបាល ទាំងគជប និងគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្តនានា គួរតែគោរពតាមស្តង់ដារទាំងឡាយ ដែលស្របនឹងស្តង់ដារអន្តរជាតិ ទាំងមុន អំឡុងពេល និងទាំងក្រោយពេលបោះឆ្នោត។ ប្រសិនបើដំណើរការបោះឆ្នោតមិនអាចទទួលបានការជឿជាក់ និងទំនុកចិត្តពីសំណាក់អ្នកបោះឆ្នោតជាទូទៅទេ នោះមូលដ្ឋានដំបូងនៃស្ថាបត្យកម្មរដ្ឋធម្មនុញ្ញ និងនយោបាយរបស់កម្ពុជា ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនឹងត្រូវបំផ្លាញ។ ក្នុងករណីនេះ ប្រទេសជាតិអាចប្រឈមនឹងហានិភ័យនៃការវិលត្រឡប់ទៅរកអំពើហឹង្សា។ ដូចនេះ រដ្ឋាភិបាលត្រូវប្រឹងប្រែងឲ្យអស់ពីលទ្ធភាព ដើម្បីបញ្ចៀសនូវស្ថានភាពបែបនេះ។ ជាការពិតណាស់ ប្រទេសជាតិត្រូវការស្ថេរភាពនយោបាយ ដើម្បីពន្លឿនដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ប៉ុន្តែស្ថេរភាពនេះ ត្រូវបង្កើតឡើងដោយឈរលើមូលដ្ឋានត្រឹមត្រូវ ស្មើភាព តម្លាភាព និងធម្មានុរូប ដើម្បីអាចឲ្យអ្នកនយោបាយទាំងអស់ នៅក្នុងសង្គមកម្ពុជា ធ្វើការចែករំលែកដោយស្មើភាពគ្នាចំពោះអភិបាល

កិច្ចរបស់ប្រទេស។ សហគមន៍អន្តរជាតិជាទូទៅ និងអង្គការសហប្រជាជាតិជាពិសេស បានវិនិយោគយ៉ាងធំធេងនៅកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីជួយប្រទេសនេះឲ្យដើរទៅមុខឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យមួយកាន់តែរឹងមាំ នីតិរដ្ឋពិតប្រាកដ និងការគោរពសិទ្ធិមនុស្សកាន់តែធំធេង។ សិទ្ធិគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ និងសិទ្ធិចូលរួមក្នុងការបោះឆ្នោតទៀងទាត់ដោយសេរី និងត្រឹមត្រូវ គឺសំខាន់ណាស់ចំពោះលទ្ធិប្រជាធិបតេយ្យណាក៏ដោយ ហើយជាពិសេសនេះគឺជាករណីសំរាប់ប្រទេសស្ថិតក្នុងអន្តរកាល ដូចកម្ពុជាជាដើម។

៦៣. គោលដៅនៃកំណែទម្រង់ការបោះឆ្នោត គួរតែធានាថា គ្មានការរំលោភបំពានកើតឡើងលើច្បាប់បោះឆ្នោត ហើយច្បាប់ទាំងនេះត្រូវតែស្របនឹងស្តង់ដារអន្តរជាតិ។ ដៃគូសន្ទនារបស់រដ្ឋាភិបាល តែងតែឆ្លើយតបចំពោះអ្នករាយការណ៍ពិសេសថា អ្វីដែលពួកគេកំពុងធ្វើ គឺស្របនឹងច្បាប់ដែលនៅធរមាន។ ទោះបីយ៉ាងណាក៏ដោយ អ្វីដែលចាំបាច់នោះគឺថា ច្បាប់ទាំងនោះត្រូវស្របតាមស្តង់ដារអន្តរជាតិដែលកើតចេញពីសន្ធិសញ្ញាដែលកម្ពុជាបានផ្តល់សច្ចាប័ន និងយុត្តិសាស្ត្រច្បាប់ដែលបង្កើតដោយស្ថាប័នសន្ធិសញ្ញានានា និងស្របតាមគោលការណ៍នៃនីតិរដ្ឋ។ កម្ពុជា គួរតែរះខ្ពស់ពីការអនុវត្តជាយន្តការនៃលទ្ធិប្រជា-ធិបតេយ្យ និងនីតិរដ្ឋ ព្រមទាំងអនុវត្តតាមគោលការណ៍ជាសារវន្ត និងស្មារតីដែលនៅពីក្រោយសញ្ញាណនៃនីតិរដ្ឋ។

៦៤. ការបោះឆ្នោតមិនត្រូវទុកជាបុព្វសិទ្ធិមួយនោះទេ ប៉ុន្តែគឺជាសិទ្ធិរបស់បុគ្គលម្នាក់ៗ និងប្រជាពលរដ្ឋគ្រប់រូប ហើយវាគឺជាភារកិច្ចរបស់អង្គការរដ្ឋទាំងអស់ ដើម្បីជួយសំរួលដល់ការអនុវត្តសិទ្ធិបែបនេះ។ នេះគឺវាពិសេសដូច្នេះ ចំពោះផ្នែកខាងនីតិប្រតិបត្តិ ដែលត្រូវបង្ហាញពីឆន្ទៈនយោបាយដ៏ចាំបាច់មួយឲ្យអនុវត្តកំណែទំរង់ដ៏ម៉ត់ចត់នៃច្បាប់ និងដំណើរការនៃការបោះឆ្នោតនៅកម្ពុជា។ កម្ពុជា បានឆ្លងកាត់លើផ្លូវដ៏វែងគ្រប់គ្រាន់មួយ ដើម្បីប្រាថ្នារៀបចំការបោះឆ្នោតដែលបំពេញបានតាមស្តង់ដារអន្តរជាតិ។ ក្នុងឋានៈជាប្រទេសមួយ ដែលបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិច្រើនជាងរដ្ឋដទៃខ្លះទៀត ហើយបច្ចុប្បន្ន ជាប្រធានអាស៊ានផងនោះ កម្ពុជាគួរតែមានបំណងចង់ក្លាយជាគំរូរបស់គេនៅក្នុងតំបន់ នៅពេលដែលខ្លួនរៀបចំការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវ ហើយគួរធ្វើអោយបានប្រសើរជាងរដ្ឋជាច្រើនដែលមានលទ្ធិប្រជាធិបតេយ្យនៅក្មេងខ្ចី។ អាស្រ័យហេតុនេះ អ្នករាយការណ៍ពិសេសចង់ទាញចំណាប់អារម្មណ៍របស់រាជរដ្ឋាភិបាល ចំពោះបញ្ហាដូចខាងក្រោមនេះ ដែលគួរតែត្រូវបានដោះស្រាយ ក្នុងការរៀបចំការបោះឆ្នោតសភាជាតិ ដែលនឹងគ្រោងធ្វើនៅខែកក្កដា ឆ្នាំ២០១៣ ខាងមុខ។

## VII. អនុសាសន៍

៦៥. គ ជ ប គួរតែមានឋានៈស្វ័យភាព និងឯករាជ្យ នៅក្នុងរចនាសម្ព័ន្ធច្បាប់ និងរដ្ឋធម្មនុញ្ញនៃកម្ពុជា ជាមួយនឹងថវិកាឯករាជ្យផ្ទាល់ខ្លួន ដែលមានការអនុម័តបែងចែកពីសភា។ ប្រធាន និងសមាជិក គ ជ ប គួរតែជ្រើសរើសចេញពីថៅក្រមជាន់ខ្ពស់ចូលនិវត្តន៍ សមាជិកជាន់ខ្ពស់និងកិត្តិយសនៃគណៈមេធាវីកម្ពុជា និងសាស្ត្រាចារ្យជាន់ខ្ពស់ផ្នែកច្បាប់ វិទ្យាសាស្ត្រនយោបាយ និងរដ្ឋបាលសាធារណៈ។

៦៦. គួរតែមានការព្រមព្រៀងគ្នាជាទូទៅខាងផ្នែកនយោបាយ ពីក្នុងចំណោមគណៈបក្សនយោបាយធំៗ ដែលមានតំណាងនៅរដ្ឋសភា ពីការតែងតាំងប្រធាន និងសមាជិក គ ជ ប និងគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត។

៦៧. រាជរដ្ឋាភិបាលគួរផ្តួចផ្តើមដំណើរការធ្វើវិសោធនកម្ម មាត្រា១៣ថ្មី ចំនុចទី២នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ ជ ប និងមាត្រាពាក់ព័ន្ធដទៃទៀត ដើម្បីធានាថា នៅក្នុងសមាសភាពគ្រប់ជាន់ថ្នាក់នៃស្ថាប័នរៀបចំការបោះឆ្នោត មានតុល្យភាពនៃតំណាងមកពីគ្រប់គណៈបក្សនយោបាយដែលមានតំណាងនៅក្នុងរដ្ឋសភា។

៦៨. ប្រធាន និងសមាជិក គ ជ ប និងគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត គួរតែត្រូវបានតែងតាំងសំរាប់អណត្តិកំណត់មួយ និងគួរមានការធានាការពារនូវតំណែងរបស់ពួកគេផង។ ពួកគេគួរតែត្រូវបានរារាំងមិនឲ្យមានតួនាទីនៅក្នុងគណៈបក្សនយោបាយក្នុងអណត្តិរបស់ពួកគេ និងរហូតដល់ទៅ២ឆ្នាំទៀតបន្ទាប់ពីផុតអណត្តិរបស់ពួកគេ។

៦៩. អ្នករាយការណ៍ពិសេស បានសំលឹងមើលយន្តការដោះស្រាយវិវាទបោះឆ្នោត ហើយយល់ឃើញថាគួរតែត្រូវបានកែលម្អ។ បច្ចុប្បន្ននេះ គឺមន្ត្រីរៀបចំការបោះឆ្នោតខ្លួនឯង ដែលត្រូវធ្វើឲ្យគេជឿជាក់លើភារកិច្ចនៃការដោះស្រាយវិវាទបោះឆ្នោតបឋម។ ដើម្បីបង្កើនជំនឿចិត្តលើគ្រប់គណៈបក្សនយោបាយនៅក្នុងដំណើរការបោះឆ្នោត ត្រូវតែធ្វើវិសោធនកម្មច្បាប់ និងបង្កើតស្ថាប័នមួយទៀត ដូចជា តុលាការពិសេសសំរាប់ការបោះឆ្នោត ឬតុលាការសំរាប់ការបោះឆ្នោត នៅក្នុងរចនាសម្ព័ន្ធតុលាការរបស់កម្ពុជា ឬជាតុលាការពិសេសសំរាប់ការបោះឆ្នោត នៅក្នុងក្រុមប្រឹក្សាធម្មនុញ្ញ គឺមិនមែន គ ជ ប ខ្លួនឯង ដែលត្រូវយកបញ្ហាពាក់ព័ន្ធនឹងវិវាទនៃការបោះឆ្នោត មកដោះស្រាយនោះទេ។

៧០. គ្រប់គណៈបក្សនយោបាយធំៗ គួរតែទទួលបានដោយយុត្តិធម៌ និងស្មើភាពគ្នានូវប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ដើម្បីបញ្ជូនសាររបស់ខ្លួនទៅកាន់អ្នកបោះឆ្នោត និងគួរតែមានឱកាសផ្សព្វផ្សាយសារនោះនៅក្នុងម៉ោងសំខាន់ៗ។ ជំហានបន្ទាប់ គួរត្រូវបង្កើតគណៈកម្មាធិការឯករាជ្យមួយសំរាប់ការគ្រប់គ្រង និង

ការប្រើប្រាស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ដែលគ្រប់គ្រងដោយរដ្ឋ ដោយអនុញ្ញាតឲ្យគណៈបក្សនយោបាយធំៗទាំងអស់ដែលមានតំណាងនៅក្នុងរដ្ឋសភា ប្រើប្រាស់ដោយពេញលេញនូវប្រព័ន្ធផ្សព្វផ្សាយទាំងនេះ រហូតដល់ថ្ងៃយុទ្ធនាការបោះឆ្នោត ដោយឈរលើជំហរស្មើភាពគ្នា។

៧១. បញ្ហាមួយផ្សេងទៀត គឺការប្រើប្រាស់ធនធានរបស់រដ្ឋដោយគណៈបក្សនយោបាយនានា នៅក្នុងពេលយុទ្ធនាការឃោសនារបស់ពួកគេ រួមទាំងពេលម៉ោងធ្វើការរបស់រដ្ឋ យានជំនិះ និងសម្ភារៈផ្សេងៗ។ រដ្ឋាភិបាលត្រូវធានាថា មន្ត្រីរាជការទាំងអស់ នគរបាល និងយោធា មិនត្រូវចូលរួមក្នុងសកម្មភាពនយោបាយណាមួយ នៅពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការរបស់ពួកគេ ដែលរាប់ទាំងការប្រើប្រាស់ធនធានរបស់រដ្ឋាភិបាល ហើយធានាថា ភាពអាព្យាក្រឹត្យ គឺជាចំណុចកំពូល។

៧២. ដើម្បីអោយការបោះឆ្នោតទទួលបានទំនុកចិត្ត គ្រប់គណៈបក្សប្រឆាំង ត្រូវតែមានសេរីភាព រៀបចំ និងឃោសនាដោយគ្មានការរារាំង និងការភ័យខ្លាច។ ការបោះឆ្នោតមិនមែនគិតត្រឹមតែថ្ងៃបោះឆ្នោតនោះទេ ក៏ប៉ុន្តែត្រូវគិតពីបរិបទសិទ្ធិមនុស្សជារួម នៅក្នុងប្រទេស។ ការតំណាងនានា ត្រូវបានផ្ញើមកអ្នករាយការណ៍ពិសេសថា មានការណីជាច្រើននៃការយាយី និងការបំភិតបំភ័យដល់ពលរដ្ឋ ដែលចូលរួមក្នុងការប្រជុំនយោបាយរបស់គណៈបក្សប្រឆាំង ដោយមន្ត្រីរដ្ឋាភិបាល និងប៉ូលីសសំងាត់។ ដូចនេះ រដ្ឋាភិបាលត្រូវតែធានាថា គណៈបក្សប្រឆាំង មានសេរីភាពធ្វើសកម្មភាពនយោបាយរបស់ខ្លួន ដោយគ្មានការយាយី និងការបំភិតបំភ័យណាមួយឡើយ មិនត្រឹមតែជុំវិញថ្ងៃបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតពីពេលដែលខិតមកជិតដល់ថ្ងៃបោះឆ្នោត និងពេញមួយអណត្តិសភាផង។

៧៣. គួរតែមាននីតិវិធីមួយដែលមានប្រសិទ្ធភាពជាង មិនលំអៀងជាង និងគ្មានការរើសអើងជាង សំរាប់ការចុះឈ្មោះអ្នកបោះឆ្នោតនៅកម្ពុជា។ អាស្រ័យហេតុនេះ អាជ្ញាធររបស់រដ្ឋាភិបាលគួរតែផ្តល់ឯកសារចាំបាច់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន និងឯកសារអាត្រានុកូលដ្ឋានចាំបាច់ដទៃទៀតដល់ពលរដ្ឋទាំងអស់ក្នុងតំលៃថោក និងឲ្យបានលឿន ហើយគួរចុះឈ្មោះអ្នកបោះឆ្នោតសារជាថ្មី ដោយប្រើប្រាស់ទិន្នន័យ ពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរធ្វើជាមូលដ្ឋាន ដើម្បីការចុះបញ្ជីថ្មីនៃអ្នកបោះឆ្នោត។

៧៤. ពលរដ្ឋខ្មែរគ្រប់រូបដែលមានសិទ្ធិបោះឆ្នោតគួរតែត្រូវបានផ្តល់សិទ្ធិឲ្យធ្វើសំណើពីការចុះឈ្មោះជាមួយអាជ្ញាធរបោះឆ្នោត ឬអាជ្ញាធរដែនដី នៅពេលណាក៏បាននៃឆ្នាំ ហើយនៅពេលដែលពួកគេទទួលបានអត្តសញ្ញាណប័ណ្ណដែលគួរតែមានសុពលភាពអស់មួយជីវិតនោះ លើកលែងតែមានការផ្លាស់ប្តូរភិនភាគរបស់ពួកគេ តម្រូវឲ្យធ្វើការផ្លាស់ប្តូរ។

៧៥.ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ២០១២ បានបង្ហាញថា បញ្ហាដ៏ជាក់លាក់នៅតែកើតមានជាមួយឯកសារបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោត ដែលត្រូវបានស្គាល់ជាទូទៅថា ទំរង់១០១៨ ជាពិសេស

ទាក់ទងនឹងការចេញឯកសារក្លែងក្លាយ និងការប្រើប្រាស់ឯកសារទាំងនេះ នៅក្នុងករណីមួយចំនួន។ គ ជ ប គួរតែពិនិត្យពីដំណើរការនៃការចេញឯកសារបែបនេះ ដើម្បីធានាថា ប្រព័ន្ធនេះមិនត្រូវបំពាន ដោយគណៈបក្សនយោបាយណាមួយ ក្នុងគោលបំណងបំរើផលប្រយោជន៍របស់ពួកគេនោះទេ និង ធានាថា គ្មានការបោះឆ្នោតមិនត្រឹមត្រូវ កើតមានឡើងលើផ្នែកនៃតួអង្គណាមួយនៅក្នុងសង្គមនោះទេ។

៧៦. គ ជ ប គួរបង្កើតវិធានការពិសេសនានា ដើម្បីធានាថា អ្នកគ្មានទីជំរក ឬអ្នកដែលត្រូវបានបណ្តេញចេញពីដីធ្លីរបស់ពួកគេថ្មីៗនេះ មិនត្រូវបានដកហូតសិទ្ធិបោះឆ្នោត នៅក្នុងការបោះឆ្នោតដែលនឹងចូលមកដល់នាពេលខាងមុខ។

៧៧. ដើម្បីអោយការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និងត្រឹមត្រូវ បរិយាកាសនយោបាយទាំងមូលគួរតែប្រព្រឹត្តទៅដោយសេរី និងនាំមកនូវការអនុវត្តសិទ្ធិ និងសេរីភាពទាំងឡាយ ដែលធានាការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាបានផ្តល់សច្ចាប័ន។ ដូចនេះ រាជរដ្ឋាភិបាលគួរតែធានាថា បុគ្គលគ្រប់រូបអាចប្រើប្រាស់សិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិ សេរីភាពនៃការជួបប្រជុំ និងសមាគម។

៧៨. ដំណើរការបោះឆ្នោត រួមមាន ដំណើរការចុះឈ្មោះអ្នកបោះឆ្នោត និងរបៀបក្នុងការដោះស្រាយវិវាទបោះឆ្នោត គួរតែមានតម្លាភាព និងស្របតាមស្តង់ដារអន្តរជាតិ។ ឧទាហរណ៍ គ ជ ប គួរបិទផ្សាយជាសាធារណៈ នូវឈ្មោះមន្ត្រីនៃការិយាល័យបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រូវផ្តល់ជូនបេក្ខជនទាំងឡាយដែលមកពីគ្រប់គណៈបក្សនយោបាយទៅតាមការស្នើសុំ ដោយផ្តល់ឲ្យពួកគាត់នូវឱកាសដើម្បីតតាំងការក្លែងបន្លំឈ្មោះ ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត។

៧៩. គ ជ ប គួរតែងតាំងអភិបាលបោះឆ្នោតដែលមានវិជ្ជាជីវៈ ដែលអាចជំនួសមេភូមិ ទាំងក្នុងពេលការចុះឈ្មោះអ្នកបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត ហើយដាក់មន្ត្រីបោះឆ្នោតឃុំ/សង្កាត់ទាំងអស់ និងដំណើរការនានា ឲ្យស្ថិតនៅក្រោមយន្តការត្រួតពិនិត្យដ៏តឹងរឹងរបស់ខ្លួន។

៨០. ច្បាប់បច្ចុប្បន្ន ដែលតម្រូវអោយបុគ្គលណាមួយដែលមានបំណងឈរឈ្មោះបោះឆ្នោត ត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតរបស់គណបក្សនយោបាយមួយ បញ្ញត្តិនេះគួរតែបានធ្វើវិសោធនកម្ម ដើម្បីផ្តល់លទ្ធភាពអោយបេក្ខជនឯករាជ្យ អាចឈរឈ្មោះបោះឆ្នោតជាតិបាន។

៨១. អាស្រ័យដោយប្រទេសកម្ពុជាអនុញ្ញាតអោយប្រជាពលរដ្ឋអាចមានសញ្ជាតិពីរ ដូច្នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរតែផ្តល់លទ្ធភាពអោយប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅក្រៅប្រទេស

អាចប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ខ្លួនបាន យ៉ាងហោចណាស់ក៏ នៅប្រទេសទាំងឡាយដែលមានតំណាងស្ថានទូត និងឬ ស្ថានកុងស៊ុលប្រចាំនៅទីនោះ ដូចការអនុវត្តន៍ក្នុងបណ្តាលប្រទេសច្រើនទៀត។

៨២. នៅទីបញ្ចប់ អ្នករាយការណ៍ពិសេស ដឹងអំពីស្ថានភាពរបស់លោកសម រង្ស៊ី ប្រធានគណបក្ស-សម រង្ស៊ី។ គាត់ត្រូវបានតុលាការផ្តន្ទាទោសពីបទចោទប្រកាន់ទាក់ទងនឹងរឿងនយោបាយ។ គួរតែស្វែងរកដំណោះស្រាយនយោបាយមួយ ដើម្បីផ្តល់លទ្ធភាពអោយគាត់ដែលជាប្រធានគណបក្សប្រឆាំងដើម្បីដើរតួនាទីមួយពេញលេញក្នុងជីវភាពនយោបាយនៅកម្ពុជា។ អ្នករាយការណ៍ពិសេសជឿជាក់ថាកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយ ដោយគណបក្សកាន់អំណាច និងគណបក្សប្រឆាំងឈានទៅការផ្សះផ្សាគ្នាជាប្រយោជន៍ដល់ដំណើរការប្រជាធិបតេយ្យមួយដែលខ្លាំង និងស៊ីជម្រៅជាងនេះថែមទៀតនៅកម្ពុជា។ ការនេះសំខាន់ជាពិសេស សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃខាងមុខ។ សំរាប់សុខសន្តិភាព និងវិបុលភាពរយៈពេលដ៏យូរអង្វែង គួរតែរក្សាអោយមានទីលានប្រកួត មួយដែលរាបស្មើសំរាប់គណបក្សនយោបាយទាំងអស់ ចូលរួមប្រកួតប្រជែងដោយស្មើភាពគ្នា។ ប្រជាពលរដ្ឋមានការជឿជាក់លើប្រព័ន្ធអភិបាលកិច្ចក្នុងប្រទេស និងក្នុងការបោះឆ្នោតតាមកាលកំណត់ ដែលជាស្នូលនៃលិទ្ធិប្រជាធិបតេយ្យ។